ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារ

# ការវិភាគប្រព័ន្ធកេ្យត្រ-បរិស្ថានថ្នាក់ឃុំ

# សម្រាប់ការ

## បណ្តុះបណ្តាលវគ្គផ្សព្វផ្សាយកសិកម្ម

១០ ឧ ម២៥

# អារម្ភកថា

| នាយកដ្ឋាន / មន្ទីរ | ផ្នែក / ជំនាញ | នាក់ |
|---|---|---|
| ការិយាល័យផ្សព្វផ្សាយកសិកម្មខេត្ត | ប្រធាន និងមន្ត្រីប្រព័ន្ធកសិកម្ម (២នាក់) | ៣ |
| ការិយាល័យជលផលខេត្ត | អ្នកជំនាញជលផល | ១ |
| មន្ទីរធនធានទឹកខេត្ត | ផ្នែកគាំទ្រដល់កសិករក្នុងការប្រើប្រាស់ទឹក | ១ |
| មន្ទីរបរិស្ថានខេត្ត | អ្នកជំនាញផ្នែកគ្រប់គ្រងធនធានធម្មជាតិ | ១ |
| មន្ទីរគ្រប់គ្រងដែនដីខេត្ត | អ្នកជំនាញគ្រប់គ្រងដីធ្លី | ១ |
| ការិយាល័យកសិកម្មស្រុក | ក្សេត្រសាស្ត្រ ផលិតកម្ម និងបសុព្យាបាល ជលផល | ២ |
| អ្នកសម្របសម្រួលវិមជ្ឈការ និងសហវិមជ្ឈការថ្នាក់ស្រុក | អ្នកជំនាញផែនការអភិវឌ្ឍន៍ឃុំ | ១ |
| ក្រុមប្រឹក្សាឃុំ និងអ្នករៀបចំផែនការអភិវឌ្ឍន៍ឃុំ | អ្នករៀបចំផែនការអភិវឌ្ឍន៍ឃុំ ឬក្រុមប្រឹក្សា អភិវឌ្ឍន៍ឃុំ | ៣ |
| តំណាងអ្នកភូមិ (ពេលធ្វើ RRA ) | តំណាងសហគមន៍ | ៣០ |

**ជំហានសម្រាប់ធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំបង្ហាញក្នុងតារាងខាងក្រោម :**

| ជំហានសម្រាប់ធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ | ទីតាំង | ចំនួនថ្ងៃ |
|---|---|---|
| **ជំហានទី ១ :** ការរៀបចំផែនការ | មន្ទីរកសិកម្មខេត្ត | ២ |
| **ជំហានទី ២ :** ប្រមូលទិន្នន័យទី ២ និងការរៀបចំ | សាលាឃុំ | ៣ |
| **ជំហានទី ៣ :** ការវិភាគទិន្នន័យលើកដំបូង | មន្ទីរកសិកម្មខេត្ត | ១ |
| **ជំហានទី ៤ :** ការវាយតម្លៃជនបទឆាប់រហ័ស | សាលាឃុំ | ២ |
| **ជំហានទី ៥ :** ការវិភាគប្រព័ន្ធ | មន្ទីរកសិកម្មខេត្ត | ៣ |
| **ជំហានទី ៦ :** ការរៀបចំរបាយការណ៍ និងបញ្ចូលទិន្នន័យ | ការិយាល័យកសិកម្មផ្សព្វផ្សាយកសិកម្មខេត្ត | ១៦ + |
| **ជំហានទី ៧ :** បទបង្ហាញដល់ក្រុមប្រឹក្សាឃុំ | សាលាឃុំ | ១ |
| **ជំហានទី ៨ :** រៀបចំផែនការអភិវឌ្ឍន៍ឃុំ ឬក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំដើម្បីគាំទ្រ | សាលាឃុំ | ១ |

**+ សំគាល់ : ចំនួនថ្ងៃសរុប/ម្នាក់ ដែលមានប្រធានការិយាល័យផ្សព្វផ្សាយកសិកម្ម មន្ត្រីផ្សព្វផ្សាយកសិកម្ម ប្រធានកសិកម្មស្រុក មន្ត្រីជលផល និងមន្ត្រីបរិស្ថាន**

# មាតិការ

**អារម្ភកថា**

**ការសាកល្បងនៅមូលដ្ឋានជនបទ**

**កម្មវិធី**

**សមាសភាពក្រុម និងទីតាំង**

**ជំហានក្នុងការវិភាគប្រព័ន្ធកសិត្រ-បរិស្ថានឃុំ**

**១. ការវិភាគតាមបែបលំហរ**............................................ ៥

❖ ការផ្លូវផ្គូងផែនទី............................................ ៥

❖ ផែនទីដលផល............................................ ៥

❖ តារាងប្រើប្រាស់ប្រភពទឹក............................................ ៧

❖ ដ្យាក្រាមពំនុសកាត់ទទឹង............................................ ៩

**២. ការវិភាគតាមបែបពេលវេលា**............................................ ១៣

❖ ប្រវិត្ត............................................ ១៣

❖ ផែនទីធនធានដលផល............................................ ១៥

❖ អន្តរកម្មរវាង ដី ទឹក កសិកម្ម ដលផល............................................ ១៥

❖ ប្រតិទិនរដូវកាល............................................ ១៨

**៣. ការវិភាគពីជីវភាពរស់នៅ**............................................ ២៧

❖ ចំណាត់ថ្នាក់ធនធាន............................................ ២៧

❖ ការវិភាគយេនឌ័រ............................................ ៣២

❖ ទ្រព្យធនជីវភាពរស់នៅ............................................ ៣៥

**៤ . ការវិភាគលំហូរ**............................................ ៣៧

❖ ដ្យាក្រាមលំហូរ............................................ ៣៧

❖ អនុផលព្រៃឈើ............................................ ៣៩

**៥. ការវិភាគសេដ្ឋកិច្ច និងការសំរេចចិត្ត**............................................ ៤0

❖ ការវិភាគហេតុ និងផល............................................ ៤0

❖ ដ្យាក្រាមវ៉ែន............................................ ៤៣

❖ ការវិភាគសេដ្ឋកិច្ច............................................ ៤៤

❖ ការវិភាគសង្វាក់ផលិតកម្ម............................................ ៤៦

❖ វិធីសាស្ត្រប្រៀបធៀបគូរបញ្ហា.......... ៤៧

**៦. ការវិភាគប្រព័ន្ធ**.......... ៤៩

❖ ការវិភាគស្ទូត.......... ៤៩

❖ ការវិភាគលក្ខណៈប្រព័ន្ធកសិក្ស-បរិស្ថាន.......... ៥១

❖ តារាងសំណួរគន្លឹះ និងគោលការណ៍ណែនាំ.......... ៥៤

❖ ការបញ្ចូលបច្ចេកវិជ្ជាថ្មី.......... ៦០

❖ ការបញ្ជាក់ផលប៉ះពាល់ (ភាពក្រីក្រ យេនឌ័រ និងបរិស្ថាន).......... ៦១

❖ យុទ្ធសាស្ត្រការគ្រប់គ្រងដី និងធនធានទឹក.......... ៦៤

## ១. ការវិភាគទិន្នន័យលំអិត

### ❖ ការផ្ទៀងផ្ទាត់ផែនទី

ការបន្ថែមផែនទីមួយចំនួនទៅលើឧបករណ៍ផែនទីដែលមានស្រាប់ ផែនទីនេះនឹងបង្ហាញអំពី ទីតាំងប្រភពទឹក រួមមាន ស្ទឹង អូរ (មានទឹកតាមរដូវ) អាងទឹក បឹង ប្រឡាយ ស្រះចិញ្ចឹមត្រី វាលភក់ និងវាលស្រែ ។ តំបន់ដីសើមទាំងនេះនឹងត្រូវកត់ត្រាបញ្ចូលទៅក្នុងផែនទី ដោយបន្ថែមព័ត៌មានមួយចំនួនដូចជា : ភាពខុសគ្នានៃប្រភពទឹក និងធ្វើការវិភាគអំពីប្រភពទឹក ។

ផែនទីជលផល និងការប្រមូលទិន្នន័យទាំងនេះ គួរចាប់ផ្តើមពីការប្រមូលទិន្នន័យលើកដំបូង និងបន្តធ្វើការកែលំអនៅពេលដំណើរការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ។ ពង្រាងផែនទីលើកដំបូង ហើយនឹងតារាងបែងចែកត្រូវបានប្រើប្រាស់ជាមួយអ្នកភូមិនៅពេលធ្វើការវាយតម្លៃជនបទឆាប់រហ័ស ទៅតាមស្ថានភាពជាក់ស្តែង និងធ្វើការកែលំអទៅលើប្រព័ន្ធព័ត៌មានជលផល ទៅតាមប្រភេទប្រភពទឹកនិមួយៗ ។

**ជំហ៊ានសំខាន់ៗ :**

១. ផែនទីជលផល និងការប្រមូលទិន្នន័យទាំងនេះ គួរចាប់ផ្តើមពីការប្រមូលទិន្នន័យលើកដំបូង និងបន្តធ្វើការកែលំអ និងធ្វើបច្ចុប្បន្នភាពនៅពេលដំណើរការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន

២. ពង្រាងផែនទីលើកដំបូង ហើយនិង តារាងបែងចែក ត្រូវបានប្រើប្រាស់ជាមួយអ្នកភូមិនៅពេលធ្វើការវាយតម្លៃជនបទឆាប់រហ័សទៅតាមស្ថានភាពជាក់ស្តែង និងធ្វើការកែលំអទៅលើប្រព័ន្ធព័ត៌មានជលផលទៅតាមប្រភេទប្រភពទឹកនិមួយៗ

៣. ផ្ទៀងផ្ទាត់មើលតារាងប្រភពទឹក នៅក្នុងឧបករណ៍ប្រើប្រាស់ទឹក ដើម្បីអោយប្រាកដថា រាល់ទិន្នន័យទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងផែនទី និងតារាងការវិភាគប្រភពទឹក

៤. ជំហ៊ានក្នុងការវិភាគផែនទីជលផលនៅក្នុងការវិភាពប្រព័ន្ធក្សេត្រ-បរិស្ថាន ដើម្បីកំណត់អន្តរអំពើសំខាន់ៗដូចជា : កសិកម្ម ការប្រើប្រាស់ដី ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្ត ។ល។

### ❖ ផែនទីធនធានជលផល

ផែនទីនេះ ត្រូវបានគេផ្តោតទៅលើ ផែនទីឃុំ ដែលបានបង្ហាញអំពីអាងទឹកធម្មជាតិសំខាន់ៗដែលមាននៅក្នុងឃុំ ដូចជា ទន្លេ ព្រែក បឹង ស្រះចិញ្ចឹមត្រី វាលល្បាប់ និង វាលស្រែ ។ល។ ក្នុងតំណាក់កាលធ្វើអង្កេតបឋមនៃការវិភាគក្សេត្របរិស្ថានឃុំ អាងទឹកធម្មជាតិ ត្រូវបានគេកត់ត្រាទុកនៅលើផែនទី ហើយពត៌មានដែលទាក់ទិនទៅនឹងអាងទឹកធម្មជាតិនីមួយៗក៏ត្រូវបានគេកត់ត្រានៅក្នុងតារាងម៉ាទ្រិចដែរ ។ផែនទីធានធានជលផល និង ទិន្នន័យដែលមានស្រាប់គួរត្រូវបន្ថែមទៀត និងកែឡើងវិញក្នុងដំណើរការធ្វើអង្កេតបឋមនៃការវិភាគក្សេត្រ-បរិស្ថានឃុំ ។ ពង្រាងផែនទីដំបូង និង ទិន្នន័យដែលមានស្រាប់ ត្រូវបានគេរៀបចំសំរាប់ធ្វើការវាយ

តម្លៃឆាប់រហ័សនៅតាមជនបទ (RRA exercise) ជាមួយអ្នកភូមិ ដើម្បីទទួលពត៌មានពិតប្រាកដកែឡើងវិញ និង ផ្តល់ព័ត៌មានធនធានជលផលបន្ថែមទៀតដែលទាក់ទងទៅនឹងប្រភេទអាងទឹកធម្មជាតិនីមួយ ។

**តារាងបញ្ជីផ្ទៀងផ្ទាត់ ផែនទីធនធានជលផល**

១. ចាប់ផ្តើម ពង្រាងផែនទី ក្នុងតំណាក់កាល ធ្វើអង្កេតបឋមនៃការវិភាគក្សេត្របរិស្ថានឃុំ និង កែលំអ និង កែវាឡើងវិញក្នុងកំឡុងពេលដំណើការធ្វើអង្កេតបឋមនៃការវិភាគក្សេត្រ-បរិស្ថានឃុំទាំងមូល ។

២. ប្រើប្រាស់ពង្រាងផែនទី ជាមួយអ្នកភូមិក្នុងតំណាក់កាលធ្វើការវាយតម្លៃឆាប់រហ័សនៅតាមជនបទ (RRA exercise) ដើម្បីទទួលបាននូវពត៌មានដែលទាក់ទិនជាមួយអាងទឹកធម្មជាតិនីមួយៗដែលកត់ត្រាទុកនៅក្នុងតារាងម៉ាទ្រិចវិភាគអាងទឹក

៣. ក្នុងដំណាក់កាលវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ ដាក់ជានផែនទីជលផល ទៅលើស្រទាប់ផែនទីផ្សេងទៀតក្នុងគោលបំនងដើម្បី បញ្ជាក់អន្តរកម្មសំខាន់ៗជាមួយកសិកម្ម ការប្រើប្រាស់ដី ការអភិវឌ្ឍន៍ធារាសាស្ត្រ ។ល។

៤. ប្រៀបធៀបប្រភពអាងទឹកនីមួយៗ នៅក្នុងតារាងម៉ាទ្រិចប្រើប្រាស់ទឹកដើម្បីធានាថា ពត៌មានទាំនេះត្រូវបានគេកត់ត្រាទុកនៅលើផែនទី និង កត់ត្រាទុកនៅក្នុងតារាងម៉ាទ្រីចវិភាគអាងទឹកផងដែរ ។

**តារាងការវិភាគប្រភពទឹក**

| ប្រភពទឹក | **បឹង** | **ស្រះ** | **ប្រភពទឹក** | **ផ្សេងៗ** |
|---|---|---|---|---|
| តំបន់ក្សេត្រ-បរិស្ថាន ដែលមានប្រភពទឹក | ១. ព្រៃលិចទឹក<br>២. វាលស្មៅលិចទឹក | ១. តំបន់ស្រូវស្រោចស្រព ដោយទឹកភ្លៀង<br>២. តំបន់ខ្ពង់រាប និង លំនៅដ្ឋាន | | |
| រដូវកាល (តាមរដូវ ឬ ជាអចិន្ត្រៃយ៍) | តាមរដូវ | ជាអចិន្ត្រៃយ៍ | | |
| ការទំនាក់ទំនង (ជាមួយប្រភាពទឹកផ្សេងទៀត) | មានទំនាក់ទំនង ជាមួយទន្លេសាប នៅរដូវវស្សា និងតភ្ជាប់ទៅស្រែប្រាំង | គ្មានទំនាក់ទំនង | | |
| គន្លឹះប៉ះពាល់ការប្រើប្រាស់ទឹក និងការបរិយា | ការប៉ះពាល់ការប្រើប្រាស់ទឹក | ការប៉ះពាល់ការប្រើប្រាស់ ទឹករវាង | | |

| | | | | |
|---|---|---|---|---|
| ដោយសង្ខេប | រវាងស្រូវរដូវប្រាំង និងការនេសាទត្រី | ដំណាំបន្លែ និង ត្រី | | |
| បទបញ្ជា នៃការប្រើប្រាស់ទឹក | ច្បាប់អនុញ្ញាតលើការប្រើប្រាស់ឧករណ៍នេសាទ | ឯកជន | | |
| ការប្រើប្រាស់ឧបករណ៍នេសាទ | មង សន្ទូច លប | បៃរ អួន | | |
| ប្រភេទត្រី | ត្រីរ៉ស់ ត្រីអណ្តែង ត្រីក្រាញ់ | ត្រីទីឡាព្យា ត្រីកាប សាមញ្ញ ត្រីកាបស | | |
| ការបំលាស់ទីរបស់ប្រភេទត្រី(ត្រីស ខ្មៅ និងប្រផេះ) | ត្រីព្រួល | គ្មាន | | |
| ផលប៉ះពាល់បរិស្ថាន | ថ្នាំពុលសត្វល្អិត នៅរដូវប្រាំង | ជំងឺត្រី | | |
| ការបង្កាត់ពូជ ចំណី ឬទីជំរក | ចំណី ទីជំរក | ចំណី ទីជំរក | | |

*** ប្រភេទប្រភពទឹកត្រូវបានបញ្ចូលទៅក្នុងការវិភាគ ដូចជា : ទន្លេ អូរ អាងស្តុកទឹក ប្រឡាយ បឹង ស្រះវាលភក់ និងវាលស្រែ**

- **តារាងប្រើប្រាស់ប្រភពទឹក**

តារាងប្រើប្រាស់ប្រភពទឹក ជាឧបករណ៍ប្រើសំរាប់ជាជំនួយក្នុងការសិក្សាអំពី ការប្រើប្រាស់ប្រភពទឹកផ្សេងៗគ្នានៅក្នុងឃុំ និងការវិភាគព័ត៌មានអំពីលក្ខណៈគន្លឹះនៃការប្រើប្រាស់ប្រភពទឹក ។

**ជំហ៊ានសំខាន់ៗ** :

១. ប្រើផែនទីប្រភពទឹក នៅពេលធ្វើការវាយតម្លៃជនបទឆាប់រហ័ស ដើម្បីកំណត់នូវរាល់ប្រភពទឹកសំខាន់ៗនៅក្នុងឃុំ និង រៀបរាប់នៅក្នុងតារាង

២. ប្រើតារាង ដើម្បីកត់ត្រានូវការប្រើប្រាស់ផ្សេងៗ និងលក្ខណៈ នៃប្រភពទឹកនិមួយៗ

៣. ត្រួតពិនិត្យលើផែនទីប្រភពទឹក ដើម្បីអោយប្រាកដថា រាល់ប្រភពទឹកសំខាន់ៗត្រូវបានប្រើប្រាស់នៅក្នុងការវិភាគ

**ឧទាហរណ៍ : តារាងប្រើប្រាស់ទឹកក្នុងឃុំ**

| ប្រភពទឹក/ការប្រើប្រាស់ | ត្រពាំង | អូរ/ប្រឡាយ | អណ្តូង | ស្ទឹង | បឹង | ព្រែក | ទន្លេ | សំគាល់ |
|---|---|---|---|---|---|---|---|---|
| **រដូវវស្សា ពីខែមិថុនា-ខែវិច្ឆិកា** | | | | | | | | |
| ចំអិនអាហារ/ហូប | ✓ | ✓ | | ✓✓ | | | | |
| បោកគក់/ងូត | ✓ | ✓ | ✓✓ | | | | | |
| ស្រោចស្រព (ស្រូវ) | ✓✓ | ✓ | | | ✓✓ | ✓ | | |
| ចិញ្ចឹមសត្វ | | ✓✓✓ | | | | ✓✓✓ | | |
| ដំណាំលក្ខណៈគ្រួសារ | ✓✓ | | ✓✓✓ | | ✓✓ | | ✓✓✓ | |
| ចិញ្ចឹមត្រី | | ✓✓ | | | | ✓✓ | | |
| ផ្សេងៗ | | ✓✓ | | | | | | |
| **ប្រភព និង លក្ខណៈធនធានទឹក** | | | | | | | | |
| បរិមាណទឹក | ✓✓ | ✓ | | | | | | |
| គុណភាពទឹក | | ✓✓✓ | | | | | | |
| ទឹកដែលមានជាប្រចាំ | ✓✓ | | ✓✓✓ | | | | | |
| ទឹកដែលអាចប្រើបានគ្រប់គ្នា | | ✓✓ | | | | | | |
| **រដូវប្រាំង ពីខែធ្នូ-ខែមិថុនា** | | | | | | | | |
| ចំអិនអាហារ/ហូប | | | | ✓✓ | ✓ | | | |
| បោកគក់/ងូត | | | | | ✓✓✓ | | | |
| ស្រោចស្រព (ស្រូវ) | | | | ✓✓ | | ✓✓✓ | | |
| ចិញ្ចឹមសត្វ | | | | | ✓✓ | | | |
| ដំណាំលក្ខណៈគ្រួសារ | ✓✓ | ✓ | | | | | | |
| ចិញ្ចឹមត្រី | | ✓✓✓ | | | | | | |
| ផ្សេងៗ | ✓✓ | | ✓✓✓ | | | | | |
| **ប្រភព និង លក្ខណៈធនធានទឹក** | | | | | | | | |
| បរិមាណទឹក | | | ✓✓ | ✓ | | | | |
| គុណភាពទឹក | | | | ✓✓✓ | | | | |
| ទឹកដែលមានជាប្រចាំ | | | ✓✓ | | ✓✓✓ | | | |
| ទឹកដែលអាចប្រើបានគ្រប់គ្នា | | | | ✓✓ | | | | |

*** **សំគាល់ ការប្រើប្រាស់ទឹក :✓✓✓ ប្រើប្រាស់ច្រើន, ✓✓ ប្រើប្រាស់ធម្មតា ✓ ប្រើប្រាស់តិចតួច 0 គ្មានការប្រើប្រាស់**

**លក្ខណៈធនធានទឹក : ✓✓✓ ល្អបង្គួរ , ✓✓ ល្អ ✓ មធ្យម 0 ខ្សោយ**

## ❖ ដ្យាក្រាមពំនុះកាត់ទទឹង

ដ្យាក្រាមពំនុះកាត់ទទឹង ប្រើប្រាស់សំរាប់ពិព័ណ៌នា និងប្រៀបធៀបតំបន់ក្សេត្រ–បរិស្ថាននិមួយៗ ដោយផ្អែកទៅលើការ ចាត់តំបន់ក្សេត្រ–បរិស្ថាន និងកត្តាសេដ្ឋកិច្ចសង្គម ដោយរួមបញ្ចូលនូវលក្ខណៈសំខាន់នៃប្រភពទឹក និងជលផល ។

**ជំហ៊ានសំខាន់ៗ :**

១. បង្កើតដ្យាក្រាមពំនុះកាត់ទទឹងជាមួយកសិករក្នុងពេលធ្វើការ វាយតម្លៃជនបទឆាប់រហ័ស ដើម្បីពិព័ណ៌នានូវរាល់កត្តា សំខាន់ៗដែលមាននៅក្នុងបញ្ជីខាងក្រោម

២. បន្តការកែលំអ និងដាក់បន្ថែមនូវព័ត៌មានថ្មី ក្នុងដ្យាក្រាមពំនុះកាត់ទទឹក ក្នុងដំណើរ ធ្វើការវិភាគប្រព័ន្ធក្សេត្រ–បរិស្ថានថ្នាក់ឃុំ

៣. ប្រើដ្យាក្រាមពំនុះកាត់ទទឹងនៅពេលធ្វើការវិភាគប្រព័ន្ធក្សេត្រ–បរិស្ថានថ្នាក់ឃុំ ដើម្បីកំណត់ញ្ហា និងសំនួរ សំរាប់បង្កើតនូវបទដ្ឋានអនុវត្តបច្ចេកវិជ្ជាសមស្រប ដើម្បីដោះស្រាយបញ្ហារបស់ពួកគាត់

**បញ្ជីពំនុះកាត់ទទឹង**

រាល់ព័ត៌មានទាំងអស់ដែលមានភាពខុសគ្នា និងរួមបញ្ចូលនៅក្នុងដ្យាក្រាមពំនុះកាត់ទទឹង

- រូបភាពតំណាងតំបន់
- ពិព័ណ៌នាទូទៅ
- ឋានលេខា
- បរិស្ថានធម្មជាតិ (សត្វព្រៃ)
- ជលសាស្ត្រ
- ប្រភពទឹកសំខាន់ៗ
- ប្រព័ន្ធធារាសាស្ត្រ
- ដី
- ការប្រើប្រាស់ដីរដូវវស្សា
- ការប្រើប្រាស់ដីរដូវប្រាំង
- ដំណាំ
- ចិញ្ចឹមសត្វ
- ជលផល
- ការប្រើប្រាស់ផ្សេងៗ
- បញ្ហាចំបង

- ឱកាស
- បញ្ហាគន្លឹះ

**ឧទាហរណ៍ : ពំនុះកាត់ទទឹងតំបន់ ផ្ទៃរងទឹកភ្លៀង**

| **បរិយាយ** | **ត្នំច័ល្លី ឬតំបន់អភិរក្សធនធានធម្មជាតិ** |
|---|---|
| |  |
| **ស្ថានភាពទូទៅ** | – ជាតំបន់ជីរាលពីជើងទៅត្បូង និងពីខាងលិចទៅកើត<br>– ទទួលរបបទឹកភ្លៀងពីតំបន់ភ្នំកាត់តាមតំបន់ជីរាលដែលមានប្រហែល ៣០០ហ.ត |
| **លក្ខណៈស្ថានភាពដី** | – ដីជីរាលមធ្យមនាំទឹកហូរចូលអាង |
| **ជលសាស្ត្រ** | – ជាតំបន់ដែលនាំទឹកហូរចូលអាងតាមរយៈអូរ ចំនួន ៣ខ្សែ |
| **ប្រភេទអាងទឹក** | |
| **ប្រភេទប្រព័ន្ធស្រោចស្រព** | |
| **បរិស្ថានធម្មជាតិ** | – មានត្រី ក្តាម ខ្យង ខ្ចៅ កង្កែប ព្រិច វាលស្មៅ<br>– កូនឈើ ក្លុង ត្បែង ឈើត្រំ ក្រឡាញ់ ព្រៃរបោះ |
| **សត្វព្រៃ** | – ជ្រូកព្រៃ លលក សារិកាកែវ ឈ្លូស ទន្សាយ |
| **ដីប្រើប្រាស់រដូវវស្សា** | – ដាំដុះស្រូវវស្សា ដំណាំរួមផ្សំ ឈើហូបផ្លែ ដំណាំឧស្សាហកម្ម (អំពៅ សណ្តែកដី សណ្តែកខៀវ) |
| **ដីប្រើប្រាស់រដូវប្រាំង** | – ដំណាំបន្លែ ស្ពៃ ឪឡឹក ម្ទេស ឈើហូបផ្លែ<br>– វាលស្មៅគោ |
| **ដី** | – ដីល្បាយខ្សាច់<br>– ដីប្រទះឡាង |
| **ដីជាតិដី** | – ដីជាតិមធ្យមងាយហូរច្រោះ |
| **ដំណាំ** | – ស្រូវវស្សា ឈើហូបផ្លែ (ស្វាយ ដូង ល្ហុង) ដំណាំបន្លែ ( ល្ពៅ ននោង ត្រាវ អំពៅ សណ្តែកគ្រប់មុខ) |

| | |
|---|---|
| **សត្វ** | –គោ ជ្រូក មាន់ ទា ពពែ ក្ងាន |
| **ការប្រើប្រាស់ផ្សេងៗទៀត** | – យកអនុផលឈើទៅធ្វើអុសដុត<br>– ផ្សិតធ្វើជាអាហារ |
| **បញ្ហាចំបងៗ** | – គ្រោះរាំងស្ងួតដើមរដូវ កណ្តាលរដូវ ចុងរដូវ<br>– សត្វមានជំងឺ (មាន់ ជ្រូក)<br>– សត្វល្អិតបំផ្លាញដំណាំស្រូវ<br>– បច្ចេកទេសដាំដុះដំណាំនៅមានកំរិត<br>– ខ្វះអណ្តូង ស្រះដើម្បីស្តុកទឹកស្រោចស្រពដំណាំ |
| **ឱកាស** | – ជំរុញការដាំដុះនៅរដូវប្រាំង និងរដូវវស្សា (ដំណាំរួមផ្សំ)<br>– ដាំដំណាំឧស្សាហកម្ម ដូចជា ម្រេច ដំឡូងមី សណ្តែកដី សណ្តែកសៀង<br>– ស្រូវស្រែវស្សា<br>– ឈើហូបផ្លែ<br>– ការចិញ្ចឹមសត្វ |
| **បញ្ហាគន្លឹះ** | – ដីមានជីជាតិល្អ អាចដាំដំណាំឧស្សាហកម្មដូចជា អំពៅ ពោតក្រហម<br>– ចិញ្ចឹមសត្វ គោ ពពែ<br>– ដំណាំរួមផ្សំ បន្លែគ្រប់មុខ អាចពង្រីកដីបន្ថែម |

## ❖ ការកំណត់ប្រភេទតំបន់ក្សេត្រ-បរិស្ថាន LAND TYPES FOR AGRO-ECOSYSTEM CHARACTERISATION




| | | | | | | |
|---|---|---|---|---|---|---|
| | | | តំបន់ដីទំនាប<br>**Bunded Paddy** | ដីណាំស្រូវ<br>**Rice Land** | តំបន់លិចទឹក តាមរដូវ<br>**Seasonally flooded** | តំបន់លិចទឹកជាអចិន្ត្រៃ<br>**Permanently flooded** |
| បន់ព្រៃភ្នំ<br>**Highland**<br><br>ជាតំបន់ដែលមានរយៈកំពស់ ខ្ពស់ ពេលខ្លះសំបូរទៅដោយភ្នំ ជាទូទៅវាមានជម្រាលទេរ។ជារើយៗ យើងឃើញជួរភ្នំទាំងនោះនៅជុំវិញព្រំប្រទល់ប្រទេស កម្ពុជាដូចជាជួរភ្នំក្រវាញនៅទិសនិរតី និងជួរភ្នំដងរែកនៅទិសខាងជើងជាដើមតំបន់ទាំងនោះស្ថិតនៅដាច់ស្រយាល និងសំបូរដោយព្រៃហើយមានដែនកំណត់សំរាប់ការងារកសិកម្ម ប៉ុន្តែវាមានប្រភពអនុផលជាច្រើន ។ | តំបន់ខ្ពង់រាប<br>**Upland**<br><br>ជាតំបន់ដែលមានរយៈកំពស់ខ្ពស់ៗជាងតំបន់ទំនាបដំណាំស្រូវ។វាមានបែបផែនជាកូនភ្នំ រឺមានឋានលេខាជិរាលខ្សោយ តំបន់នេះមិនមែនលិចទឹកតាមរដូវទេហើយអាចដាំដំណាំឈើហូបផ្លែ និងដំណាំស្រូវខ្ពង់រាប។ | តំបន់ទំនាបខ្ពស់<br>**Lowland upperterrace**<br><br>ជាដីទំនាបសំរាប់ដំណាំ ស្រូវ ដីមានដក់ទឹករយៈពេលខ្លីជាងតំបន់ទំនាបទាប។តាមទម្លាប់គេដាំវានៅរដូវវស្សាដោយប្រើពូជស្រូវស្រាល។ គេមិនអាចធ្វើវាបានទេនៅរដូវប្រាំង។ | តំបន់ទំនាបមធ្យម<br>**Lowland mid terrace**<br><br>ជាដីទំនាបសំរាប់ដំណាំស្រូវ ដែលនៅចន្លោះរវាងតំបន់ទំនាបខ្ពស់ និងតំបន់ទំនាបទាប។ តាមធម្មតាគេធ្វើវានៅរដូវវស្សាដោយប្រើពូជស្រូវកណ្តាល។ | តំបន់ទំនាបទាប<br>**Lowland low terrace**<br><br>ជាដីទំនាបសំរាប់ដំណាំស្រូវលិចទឹករយៈពេលយូរជាងតំបន់ទំនាប់មធ្យម ។ តាមទម្លាប់គេដាំវានៅរដូវវស្សា ដោយប្រើពូជស្រូវធ្ងន់។ កន្លែងខ្លះអាចមានការលិចទឹករយៈពេលយូរ។ | តំបន់ដីលិចទឹកតាមរដូវ<br>**Seasonally flooded**<br><br>ជាតំបន់ដែលមានជីរៅទឹកជ្រៅ ហើយលិចទឹករយៈពេលយូរ ។ ការលិចទឹកនេះវាផ្តល់ឱ្យព្រៃលិចទឹក និងវាជាតំបន់ដំណាំស្រូវប្រដេញទឹក ។ | តំបន់ប្រភពទឹក<br>**Water resource**<br><br>ជាតំបន់លិចទឹកពេញមួយឆ្នាំ ប៉ុន្តែវាជា កន្លែងនេសាទត្រី រឺការដាំដំណាំបណ្តែតទឹក.។ |

## ២. ការវិភាគប្រវត្តិតាមបែបពេលវេលា

❖ **ប្រវត្តិ**

គំរូការវិភាគប្រវត្តិ ប្រើសំរាប់ធ្វើការវិភាគរយៈពេលយូរ និងដើម្បីកំណត់បញ្ហាគន្លឹះអោយមាននិរន្តភាពគោលបំណងមានពីរប្រភេទ :

១. គឺដើម្បីកំណត់និន្នាការរយៈពេលយូរ ឧទាហរណ៍ : ការផ្លាស់ប្តូរគំរប ព្រៃឈើ និន្នាការទិន្នផលស្រូវ ការផ្លាស់ប្តូរប្រព័ន្ធជីវភាពរស់នៅ ។ល។

២. គេប្រើប្រាស់ប្រព័ន្ធក្សេត្រ–បរិស្ថានទាំងនោះ ដើម្បីឱ្យមានភាពប្រសើរឡើងវិញ ដែលមានព្រឹត្តិការណ៍សំខាន់ៗដូចជា : ទឹកជំនន់ គ្រោះរាំងស្ងួត ជំងឺ ការប្រែប្រួលទីផ្សារ ។ល។

**ជំហ៊ានសំខាន់ៗ** :

១. នៅពេលធ្វើការវាយតម្លៃជនបទឆាប់រហ័ស រយៈពេលថ្មីទាក់ទងនឹងប្រវត្តិស្ថិតនៅខាងឆ្វេងដៃ (មើលក្នុងឧទាហរណ៍)

២. ធ្វើការវិភាគពិប្រវត្តិទាក់ទងនឹងចំនុចសំខាន់ៗ និងរយៈពេលដែលយើងកត់សំគាល់ និងព្រឹត្តិការណ៍សំខាន់ក្នុងប្រព័ន្ធជីវភាពរស់នៅដោយធ្វើការកំណត់ពីបញ្ហាឬសគល់ ដើម្បីពិភាក្សាជាមួយកសិករ រកអោយឃើញពីបញ្ហាសមស្រមនៅពេលបច្ចុប្បន្នដែលមានទំនាក់ទំនងទៅនឹងអតីតកាលរបស់ពួកគេ ។

**បញ្ជីការវិភាគប្រវត្តិ**

ការវិភាគប្រវត្តិនឹងយកបញ្ហាទៅពិភាក្សាជាមួយអ្នកភូមិមានដូចខាងក្រោម :

❖ និន្នាការប្រែប្រួល ភូមិសាស្ត្រ

❖ និន្នាការប្រែប្រួល សេដ្ឋកិច្ច

❖ការប្រែប្រួលគោលនយោបាយ

❖ការប្រែប្រួលក្នុងការប្រើប្រាស់ និងប្រាស្រ័យទាក់ទង

❖ការប្រែប្រួលប្រព័ន្ធគ្រប់គ្រងដី និងទំហំដីកាន់កាប់

❖ ព្រឹត្តិការណ៍សំខាន់ៗក្នុងការអភិវឌ្ឍន៍ (ផ្លូវ សាលារៀន សេវាសុខភាព ។ល។)

❖ និន្នាការផ្លាស់ប្តូរដីធ្លី

❖ ការប្រែប្រួលគំរបព្រៃឈើ

❖ ការប្រែប្រួលធនធានធម្មជាតិ និងអនុផលព្រៃឈើ

❖ ការប្រែប្រួលបច្ចេកទេសកសិកម្ម

❖ និន្នាការប្រែប្រួលទិន្នផលស្រូវ

- និន្នាការប្រែប្រួលដីជាតិដី
- ជំងឺសត្វពាហនៈ
- ប្រវត្តិអភិវឌ្ឍធារាសាស្ត្រ
- ព្រឹត្តិការណ៍គ្រោះរាំងស្ងួតកើតឡើង
- ផលប៉ះពាល់នៃគ្រោះរាំងស្ងួត (កសិកម្ម និងជលផល)
- ព្រឹត្តិការណ៍ទឹកជំនន់
- ផលប៉ះពាល់គ្រោះទឹកជំនន់ (កសិកម្ម និងជលផល)
- ការប្រែប្រួលអាកាសធាតុ ទឹកភ្លៀង
- ការប្រែប្រួលជលសាស្ត្រ ( ស្ទឹង ព្រែក ប្រឡាយ ស្រះ )
- ការប្រែប្រួលគុណភាពទឹក
- ការប្រែប្រួលជីរកត្រី (ផលិតផល ពូជ និងការបាត់បង់)
- ជំងឺត្រី
- ប្រវត្តិ និងការអភិវឌ្ឍន៍វារីជាតិ
- ការប្រែប្រួលប្រជាជននេសាទត្រីនៅក្នុងឃុំ
- ការផ្លាស់ប្តូរនេសាទត្រី (ឧទាហរណ៍ : ឥឡូវនេសាទត្រីក្នុងស្រែច្រើនជាងនេសាទតាមបឹងធម្មជាតិ)
- ការប្រែប្រួលបច្ចេកទេសនេសាទត្រី /ឧបករណ៍ទំនើប

**ឧទាហរណ៍ ប្រវត្តិឃុំ**

ពិព័ណ៌នាព្រឹត្តិការណ៍សំខាន់ៗដែលកើតឡើងកន្លងមកៈ

១៩៥០ – នៅក្នុងភូមិកសិករចាប់ផ្តើមដាំដុះស្រូវឡើងទឹក, ទិន្នផល ២,៥តោន/ហត

១៩៥៤ – កសិករជួបកង្វះស្បៀងដូចនេះ កសិករបង្ខំចិត្តហូបមើមក្តួច

១៩៥៧ – កសិករបានប្រើប្រាស់ជីផូស្វាត, អ៊ុយរ៉េ ដោយធ្វើការបង្ហាញមួយគ្រួសារ

១៩៧៣ –ខ្វះកំលាំងពលកម្មនៅក្នុងគ្រួសារពីព្រោះបុរស និង ស្រ្តី ស្ទើរទាំងអស់ត្រូវចូលធ្វើ ទាហ៊ានខ្មែរក្រហម

១៩៧៦ – សម័យប៉ុលពត

១៩៧៩ – ក្រុមសាមគ្គីផលិតកម្មកសិកម្ម

១៩៨០ –៩០ – កសិករផុលផុសដាំឱឡឹក ហើយចាប់ផ្តើមប្រើប្រាស់ថ្នាំពុល

១៩៩០–បច្ចុប្បន្ន – ...............

❖ **ផែនទីធនធានជលផល**

ផែនទីនេះ ត្រូវបានគេផ្តោតទៅលើ ផែនទីឃុំ ដែលបង្ហាញអំពីអាងទឹកធម្មជាតិសំខាន់ៗដែលមាននៅក្នុងឃុំដូចជា ទន្លេ ព្រែក បឹង ស្រះចិញ្ចឹមត្រី វាលល្បាប់ និងវាលស្រែ ។ល។ ក្នុងតំណាក់កាលធ្វើអង្កេតបឋមនៃការវិភាគប្រព័ន្ធកៀ្សត្រ–បរិស្ថានឃុំ អាងទឹកធម្មជាតិត្រូវបានគេកត់ត្រាទុកនៅលើផែនទី ហើយព័ត៌មានដែលទាក់ទិនទៅនឹងអាងទឹកធម្មជាតិនីមួយៗ ក៏ត្រូវបានគេកត់ត្រាទុក នៅក្នុងតារាងម៉ាទ្រិចដែរ ។

ផែនទីធនធានជលផល និងទិន្នន័យដែលមានស្រាប់គួរត្រូវបន្ថែមទៀត និងកែឡើងវិញក្នុងដំណើរការធ្វើអង្កេតបឋមនៃការវិភាគប្រព័ន្ធកៀ្សត្រ–បរិស្ថានឃុំ ។ ពង្រាងផែនទីដំបូង និងទិន្នន័យដែលមានស្រាប់ត្រូវបានគេរៀបចំសំរាប់ធ្វើការវាយតម្លៃឆាប់រហ័សនៅតាមជនបទជាមួយកសិករ ដើម្បីទទួលព័ត៌មានពិតប្រាកដកែឡើងវិញ និងផ្តល់ព័ត៌មានធនធានជលផលបន្ថែមទៀតដែលទាក់ទងទៅនឹងប្រភេទអាងទឹកធម្មជាតិនីមួយ ។

**ការពងបញ្ចីផ្សេងផ្ទាត់ ផែនទីធនធានជលផល**

១. ចាប់ផ្តើមពង្រាងផែនទី ក្នុងតំណាក់កាល ធ្វើអង្កេតបឋមនៃការវិភាគប្រព័ន្ធកៀ្សត្រ–បរិស្ថានឃុំ និងកែលំអព្រមទាំងធ្វើការកែ វាឡើងវិញក្នុងកំឡុងពេលដំណើការ ធ្វើអង្កេតបឋមនៃការវិភាគប្រព័ន្ធកៀ្សត្រ–បរិស្ថាន ឃុំទាំងមូល ។
២. ប្រើប្រាស់ ពង្រាងផែនទី ជាមួយកសិករ ក្នុងតំណាក់កាលធ្វើការវាយតម្លៃឆាប់រហ័សនៅតាមជនបទ ដើម្បីទទួលបាននូវព័ត៌មានដែលទាក់ទិនជាមួយអាងទឹកធម្មជាតិនីមួយៗ ដែលកត់ត្រាទុកនៅក្នុងតារាងម៉ាទ្រិចវិភាគអាងទឹក
៣. ក្នុងដំណាក់កាលវិភាគប្រព័ន្ធកៀ្សត្រ–បរិស្ថានឃុំ ដាក់ជាន់ផែនទីជលផល ទៅលើស្រទាប់ផែនទីផ្សេងទៀតក្នុងគោលបំណងដើម្បីបញ្ជាក់អន្តរកម្មសំខាន់ជាមួយ កសិកម្ម ការប្រើប្រាស់ដី ការអភិវឌ្ឍន៍ធារាសាស្ត្រ ។ល។
៤. ប្រៀបធៀបប្រភពអាងទឹកនីមួយៗ នៅក្នុងតារាងម៉ាទ្រិចប្រើប្រាស់ទឹកដើម្បីធានាថា ព័ត៌មានទាំងនេះត្រូវបានគេកត់ត្រាទុកនៅលើផែនទី និង កត់ត្រាទុកនៅក្នុងតារាងម៉ាទ្រីចវិភាគអាងទឹកផងដែរ ។

## **អន្តរកម្មរវាង ដី ទឹក កសិកម្ម និង ជលផល**

ដោយមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងការប្រើប្រាស់ទឹក និងដី ក្នុងប្រទេសកម្ពុជា និងអនុតំបន់អាងទន្លេមេគង្គ បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើ កសិកម្ម និងជលផលក្នុងតំបន់ ។ ដោយសារទីតាំងប្រទេសកម្ពុជាស្ថិតនៅក្នុងអាងទន្លេមេគង្គក្រោម ប្រទេសនេះក៏ទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរជាមួយបណ្តាលខេត្តដែលមានព្រំប្រទល់ជាប់នឹងអាងទន្លេមេគង្គ និង អាងទន្លេសាប ។ ប្រសិនបើភ្នាក់ងារអភិវឌ្ឍន៍ និង ស្រាវជ្រាវ កសិកម្ម និង ជលផល អាចដោះស្រាយ និង ទទួលយកនូវការផ្លាស់ប្តូរនេះពួកគេនឹង

ចាំបាច់ត្រូវឱ្យ យល់យ៉ាងច្បាស់អំពីដំណើរការ ដែលបានកើតឡើង ហើយទទួលរងនូវផលប៉ះពាល់ដល់កសិកម្ម និង ជលផលនៅ ថ្នាក់មូលដ្ឋានយ៉ាងដូចម្តេច?

តារាងម៉ាទ្រិចស្តីពី ការឆ្លើយតប និង ផលប៉ះពាល់ពី ដី កសិកម្ម ទឹក និង ជលផល គឺ ជាឧបករណ៍សាមញ្ញមួយដែលគេបង្កើតឡើងសំរាប់ប្រើប្រាស់ជាមួយកសិករ និងអ្នកនេសាទ ដើម្បីបង្កឱ្យយល់ពីការផ្លាស់ប្តូរ ដែលបានកើតឡើងដូចជា ផលប៉ះពាល់របស់ពួកគេយ៉ាងដូចម្តេច ហើយពួកគេមានយុទ្ធសាស្រ្តឆ្លើយតបយ៉ាងដូចម្តច? តារាងម៉ាទ្រិចស្តីពី ការឆ្លើយតប និង ផលប៉ះពាល់ពី ដី កសិកម្ម ទឹក និង ជលផល ត្រូវបានគេបង្កើតឡើងសំរាប់ប្រើប្រាស់ក្នុងតំណាក់កាលធ្វើការវាយតម្លៃឆាប់រហ័សនៅតាមជនបទ នៃការវិភាគប្រព័ន្ធក្បេត្រ-បរិស្ថានឃុំ ហើយលទ្ធផលរបស់វានឹងត្រូវបានគេយកទៅប្រើនៅក្នុងតំណាក់កាលវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ ដើម្បីរកឱ្យឃើញនូវបញ្ហាគន្លឹះដែលបង្កផលប៉ះពាល់ដល់កសិកម្ម និង ជលផល និង បង្កើតនូវសំនួរសំខាន់ ហើយនឹងស្នើឡើងនូវដំណោះស្រាយចំពោះបញ្ហាទាំងអស់នេះ (គោលការណ៍អនុវត្តន៍តាមបែបបច្ចេកទេស) ។ តារាងម៉ាទ្រិចស្តីពីការឆ្លើយតប និង ផលប៉ះពាល់ពី ដី កសិកម្ម ទឹក និង ជលផល មានដំណើការដូចតទៅ :

**តារាងបញ្ជីផ្ទៀងផ្ទាត់ ស្តីពី ការឆ្លើយតប និង ផលប៉ះពាល់ពី ដី កសិកម្ម ទឹក និង ជលផល**

១. ប្រើប្រាស់លទ្ធផលវិភាគពេលវេលា ដើម្បីបង្ហាញឱ្យឃើញនូវការផ្លាស់ប្តូរនៃការប្រើប្រាស់ទឹក និង ដី យ៉ាងខ្លាំងក្លា ដែលកំពុងតែកើតឡើងនៅក្នុងតំបន់ ក្សេត្របរិស្ថាននីមួយៗ ។
២. តាមរយៈការពិភាក្សាជាមួយកសិករ និង អ្នកនេសាទ ការវាយតម្លៃពីផលប៉ះពាល់នៃការផ្លាស់ប្តូរទៅលើកសិកម្ម និង ជលផល ហើយតើកសិករ និងអ្នកនេសាទទាំងនោះកំពុងទទួលយកនូវផលប៉ះពាល់ទាំងនោះ យ៉ាងដូចម្តេច?
៣. ក្នុងដំណាក់កាលវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ យើងនឹងប្រើប្រាស់ តារាងបញ្ជីផ្ទៀងផ្ទាត់ការឆ្លើយតប និង ផលប៉ះពាល់ពី ដី កសិកម្ម ទឹក និង ជលផលដែលបំពេញរួច ដើម្បីរកឱ្យឃើញនូវសំនួរគន្លឹះ ហើយនឹងបង្កើតនូវគោលការណ៍អនុវត្តន៍តាមបែបបច្ចេកទេសដ៏សមស្របសំរាប់ដោះស្រាយនូវបញ្ហាទាំងអស់នេះ ។ល។

**តារាងបញ្ជីផ្ទៀងផ្ទាត់ ការឆ្លើយតប និង ផលប៉ះពាល់ពី ដី កសិកម្ម ទឹក និង ជលផល**

| **ការប្រែប្រួលនៅលើ ការប្រើប្រាស់ទឹក និង ជលផល** | **ផលប៉ះពាល់នៅលើ កសិកម្ម នេសាទ និង ការចិញ្ចឹមជីវិត** | **ការឆ្លើយតបរបស់កសិករ និង អ្នកនេសាទ** |
|---|---|---|
| **ការកើនឡើងចរន្តទឹកហូរយ៉ាងគំហុក និង ការថយចុះចរន្តទឹកហូរ នៅតាមដងទន្លេមេគង្គ ដោយសារ** | – គ្រោះមហន្តរាយដល់ស្រូវវស្សាបានកើនឡើង<br>– មានការកើនឡើងពីការផ្លាស់ប្តូរ | – ផ្លាស់ប្តូរពេលវេលាធ្វើស្រែវស្សា<br>– បាត់ការចាប់អារម្មណ៍ ការ |

| | | |
|---|---|---|
| **ការបំផ្លិចបំផ្លាញ ដី នៅតាមដងទន្លេមេគង្គលើ** | ប្រព័ន្ធកសិកម្ម នៅតំបន់ទន្លេសាប<br>– បំរែបំរួលអេកូឡូស៊ីត្រីនៅតាមវាលស្រែ<br>– បំរែបំរួលទីជម្រកត្រីនៅតាមវាល ទំនាបដងទន្លេសាប<br>– ខ្វះខាតទឹកសំរាប់ធារាសាស្ត្រនៅរដូវប្រាំង | ចិញ្ចឹមត្រីនៅតាមវាលស្រែ<br>– ផ្លាស់ប្តូរទីកន្លែងនេសាទ<br>– លក្ខន្តិកៈថ្មីមានការតឹងតែងទៅលើ បច្ចេកទេស និង ការប្រើឧបករណ៍នេសាទ |
| **ការកើនឡើងទឹកជំនន់នៅតំបន់វាលទំនាបទន្លេសាប** | – ទិន្នផលស្រូវឡើងទឹកថយចុះដែលមិនអាចធានាបានជាមួយទឹកឡើង<br>– ហើយក៏មានគ្រោះមហន្តរាយខ្ពស់ផងដែរជាមួយការធ្វើស្រូវឡើងទឹក<br>– ការបាត់បង់ទីជម្រកត្រី<br>– បំរែបំរួលអេកូឡូស៊ីត្រីនៅតាមបឹង | – ការផ្លាស់ប្តូរដីទៅធ្វើស្រែស្រាល នៅរដូវប្រាំងជាមួយអាងទឹក<br>– ការបន្ថយតំបន់ស្រូវបណ្តែតទឹក<br>– សំណូមពរឱ្យមានបច្ចេកទេសធ្វើស្រូវប្រាំងបានកើនឡើង<br>– ផ្លាស់ប្តូរបច្ចេកទេសនេសាទ និង ទីកន្លែងនេសាទ |
| **ការបំផ្លិចបំផ្លាញព្រៃលិចទឹកក្នុងអាងទឹកទន្លេសាបដែលបណ្តាលឱ្យជន់លិចទឹកតាមដងទន្លេ ព្រែក វាលស្រែ និងកើនឡើងនូវកំណកនៅតាមដងទន្លេសាបក្នុងរដូវវស្សា ហើយក៏កាត់បន្ថយចរន្តទឹកហូរនៅតាមដងស្ទឹងក្នុងរដូវប្រាំង** | – ការជន់លិចស្រូវវស្សាបានកើនឡើង<br>– ល្បាប់ភក់នៃសំណង់ធារាសាស្ត្រក៏បានកើនឡើង<br>– បំរែបំរួលផលចាប់ត្រីនៅតាមវាលស្រែ<br>– ការប្រែប្រួលការធ្វើចរាចររបស់ត្រីពីវាលស្រែ ទៅតាមបឹង និង ព្រែក ប្រឡាយ<br>– ខ្វះខាតទឹកសំរាប់ការចិញ្ចឹមត្រី | – ការចិញ្ចឹមត្រីក្នុងស្រែបានកាត់បន្ថយ<br>– ការចាប់អារម្មណ៍ចិញ្ចឹមត្រីមានកំរិតទាប<br>– ផ្លាស់ប្តូរបច្ចេទេសនេសាទនៅតាមទន្លេ |

## ❖ ប្រតិទិនរដូវកាល

ប្រតិទិនរដូវកាល ប្រើសំរាប់វិភាគពីពេលវេលាទាក់ទងទៅនឹងការប្រែប្រួលនៃតំបន់ក្សេត្រ-បរិស្ថាននិមួយៗ ក្នុងកំឡុងពេលមួយឆ្នាំ ។ ឧបករណ៍នេះមានតំលៃ ដើម្បីអោយយល់ដឹងពីស្ថេរភាពដែលទាក់ទងទៅនឹងការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ។

**ជំហ៊ានសំខាន់ៗ :**

១. នៅពេលធ្វើការវាយតម្លៃជនបទឆាប់រហ័ស រៀបចំនិងបង្កើតប្រតិទិនរដូវកាលជាមួយអ្នកភូមិដែលមាននៅក្នុងឧទាហរណ៍ស្រាប់

២. ប្រើប្រាស់ប្រតិទិនរដូវកាល ដើម្បីពិភាក្សាជាមួយអ្នកភូមិ អំពីប្រព័ន្ធជីវភាពរស់នៅរបស់ពួកគេ

៣. ប្រើប្រាស់ប្រតិទិនរដូវកាលដើម្បីប្រមូលទិន្នន័យពីបំរែបំរួលពេលវេលាក្នុងការប្រកបមុខរបរដូចជាប្រព័ន្ធកសិកម្មដែលអាចបង្កើនទិន្នផល តំលៃប្រសើរជាង បង្កើនប្រាក់ចំណូល កាត់បន្ថយហានិភ័យពីអាកាសធាតុ ឬក៏វិបត្តិសេដ្ឋកិច្ច ឬក៏ឧបសគ្គកំលាំងពលកម្ម ។ល។

៤. នៅពេលធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ ប្រើប្រាស់ប្រតិទិនរដូវកាលដើម្បីជាសក្តានុពលបង្កើតបទដ្ឋាន អនុវត្តបច្ចេកវិជ្ជា ដែលអាចកាត់បន្ថយឧបសគ្គ ឬក៏តំលៃទីផ្សារប្រែប្រួល

**បញ្ជីប្រតិទិនរដូវកាលមានគន្លងដូចតទៅ :**

- ❖ អាកាសធាតុ ( ទឹកភ្លៀង និងសីតុណ្ហភាព )
- ❖ ជលសាស្ត្រ ( ពេលវេលាទឹកជំនន់ ជន់លិចស្រែ ហានិភ័យនៃគ្រោះរាំងស្ងួត ទឹកក្រោមដី )
- ❖ ដំណាំស្រូវ ( ស្រូវដើមរដូវ ស្រូវស្រាល ស្រូវធ្ងន់ ស្រូវខ្ពង់រាប ស្រូវបណ្តែតទឹក ស្រូវប្រាំង ស្រូវវ៉ារ )
- ❖ ដំណាំ និងបន្លែ ( ដំណាំសំខាន់ៗ )
- ❖ ដំណាំឈើហូបផ្លែ ( សកម្មភាពសំខាន់ៗសំរាប់ដំណាំហូបផ្លែ )
- ❖ បសុសត្វ ( ជម្ងឺ ខ្វះចំណី ។ល។ សត្វពាហនៈ ជ្រូក មាន់ )
- ❖ ជលផល ( ទីតាំង ឧបករណ៍ប្រើប្រាស់ រដូវត្រីពង រដូវកាលបំលាស់ទី )
- ❖ បំលាស់ទីរកការងារក្រៅពីកសិកម្ម
- ❖ ប្រាក់ចំណូលចំបងៗក្នុងមួយឆ្នាំ
- ❖ សកម្មភាពប្រាក់ចំណូលប្រចាំឆ្នាំ ( ស្រូវ ដំណាំសំខាន់ៗ សត្វពាហនៈ និងត្រី )

**ឧទាហរណ៍៖ ប្រតិទិននៃរដូវកាល ដាំដុះ ការចិញ្ចឹមសត្វ អាកាសធាតុ និង កំលាំងពលកម្ម**

| **បរិយាយ** / **ខែ** | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អាកាសធាតុ** | | | | | | | | | | | | | | | | | | |
| - សីតុណ្ហភាព | | | | | | | | | | | | | | | | | | |
| - កំរិតទឹកភ្លៀង | | | | | | | | | | | | | | | | | | |
| **ដំណាំស្រូវ** | | | | | | | | | | | | | | | | | | |
| - **តំបន់ទំនាបមធ្យម** | | | | | | | | | | | | | | | | | | |
| ស្រូវស្រាល | | | | | | | | | | | | | | | | | | |
| ស្រូវកណ្តាល | | | | | | | | | | | | | | | | | | |
| ស្រូវធ្ងន់ | | | | | | | | | | | | | | | | | | |
| - **តំបន់ទំនាបទាប** | | | | | | | | | | | | | | | | | | |
| ស្រូវឡើងទឹក | | | | | | | | | | | | | | | | | | |
| **ដំណាំបន្លែ** | | | | | | | | | | | | | | | | | | |
| - **តំបន់ទំនាបមធ្យម** | | | | | | | | | | | | | | | | | | |
| ននោង ត្រឡាច ល្ពៅ | | | | | | | | | | | | | | | | | | |


បរិយាយ
ខែ
១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ១១ ១២ ១ ២ ៣ ៤ ៥ ៦
សណ្តែកទ្រើង
ត្រសក់
- តំបន់ទំនាបទាប
បន្លែគ្រប់មុខ (ត្រសក់,ត្រប់,ននោង)
ដំណាំរួមផ្សំ
- តំបន់ទំនាបមធ្យម
ដំឡូងជ្វា
ដំឡូងមី
ដំណាំឈើហូបផ្លែ
ដាំ
ដំណាំស្វាយ
ដំណាំដូង
ដំណាំខ្នុរ
ដំណាំចេក
ដំណាំក្រូចឆ្មា
ការចិញ្ចឹមសត្វ
ជំងឺ
- គោ / ក្របី

| **បរិយាយ** / **ខែ** | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សារទឹក | | | | | | | | | | | | | | | | | | |
| អ៊ុតក្តាម | | | | | | | | | | | | | | | | | | |
| រឹងជើង | | | | | | | | | | | | | | | | | | |
| – ជ្រូក | | | | | | | | | | | | | | | | | | |
| ប៉េស្ត | | | | | | | | | | | | | | | | | | |
| សាទឹក | | | | | | | | | | | | | | | | | | |
| កញ្ច្រិល | | | | | | | | | | | | | | | | | | |
| ទន់ជើង, រាគ | | | | | | | | | | | | | | | | | | |
| អ៊ុតក្តាម, គ្រុនពោះវៀន | | | | | | | | | | | | | | | | | | |
| – មាន់ | | | | | | | | | | | | | | | | | | |
| អាសន្នរោគ | | | | | | | | | | | | | | | | | | |
| អ៊ុត | | | | | | | | | | | | | | | | | | |
| ញ៉ូកាស់ | | | | | | | | | | | | | | | | | | |
| – ទា | | | | | | | | | | | | | | | | | | |
| អាសន្នរោគ | | | | | | | | | | | | | | | | | | |
| **កំលាំងពលកម្មក្នុងភូមិ** | | | | | | | | | | | | | | | | | | |

| បរិយាយ / ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **តំបន់ទំនាបមធ្យម** | | | | | | | | | | | | | | | | | | |
| **ស្រូវវស្សា ( ស្រាល )** | | | | | | | | | | | | | | | | | | |
| – ការរៀបចំដី (ប:90%-ស: 10%) | | | | | | | | | | | | | | | | | | |
| - ការត្រាំពូជ (ប:១0%–ស:៩0%) | | | | | | | | | | | | | | | | | | |
| - ការសាប (ប:២0%-ស:៨0%) | | | | | | | | | | | | | | | | | | |
| – ការដក–ស្ទូង (ប:៣0%–ស: ៧0%) | | | | | | | | | | | | | | | | | | |
| - ការដាក់ជី ថែទាំ (ប:៨0%-ស: ២0%) | | | | | | | | | | | | | | | | | | |
| - ប្រមូលផល (ប:៥0%-ស: ៥0%) | | | | | | | | | | | | | | | | | | |
| **ស្រូវកណ្តាល** | | | | | | | | | | | | | | | | | | |
| – ការរៀបចំដី (ប:៩0%-ស: ១0%) | | | | | | | | | | | | | | | | | | |
| – ការត្រាំពូជ ធ្វើថ្នាល សាប (ប:២0%-ស:៨0%) | | | | | | | | | | | | | | | | | | |
| – ការដក–ស្ទូង (ប:៣0%-ស: ៧0%) | | | | | | | | | | | | | | | | | | |
| – ការដាក់ជី ថែទាំ (ប:៨0%–ស: ២0%) | | | | | | | | | | | | | | | | | | |
| – ការប្រមូលផល (ប:៥0%–ស: ៥0%) | | | | | | | | | | | | | | | | | | |
| **ស្រូវធ្ងន់** | | | | | | | | | | | | | | | | | | |
| - ការរៀបចំដី (ប:៦0%–ស: ៤0%) | | | | | | | | | | | | | | | | | | |

| បរិយាយ ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| - ការត្រាំពូជ ធ្វើថ្នាល សាប (ប:២០% -ស:៨០%) | | | | | | | | | | | | | | | | | | |
| - ការដក-ស្ទូង (ប:២០%-ស: ៨០%) | | | | | | | | | | | | | | | | | | |
| - ការដាក់ជី ថែទាំ (ប:៨០% -ស: ២០%) | | | | | | | | | | | | | | | | | | |
| - ការប្រមូលផល (ប:៥០%-ស: ៥០%) | | | | | | | | | | | | | | | | | | |
| **តំបន់ទំនាបទាប** | | | | | | | | | | | | | | | | | | |
| **ស្រូវឡើងទឹក** | | | | | | | | | | | | | | | | | | |
| - ការរៀបចំដី (ប:៨០% -ស: ២០%) | | | | | | | | | | | | | | | | | | |
| - ពង្រួស (ប:២០% -ស:៨០%) | | | | | | | | | | | | | | | | | | |
| - ការថែទាំ (ប:៦០% -ស: ៤០%) | | | | | | | | | | | | | | | | | | |
| - ការប្រមូលផល (ប:៥០% -ស: ៥០%) | | | | | | | | | | | | | | | | | | |
| - ការរៀបចំដី (ប:៥០% -ស: ៥០%) | | | | | | | | | | | | | | | | | | |
| - ការត្រាំពូជ ធ្វើថ្នាល សាប (ប:៨០5 -ស:២០%) | | | | | | | | | | | | | | | | | | |
| - ការដក-ស្ទូង (ប:៥០% -ស: ៥០%) | | | | | | | | | | | | | | | | | | |
| - ការដាក់ជី ថែទាំ (ប:៩០% -ស: ១០%) | | | | | | | | | | | | | | | | | | |
| - ការប្រមូលផល (ប:៥០% -ស: ៥០%) | | | | | | | | | | | | | | | | | | |
| **បន្លែ:** | | | | | | | | | | | | | | | | | | |

| បរិយាយ / ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១0 | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **តំបន់ទំនាបមធ្យម** | | | | | | | | | | | | | | | | | | |
| **ននោង ត្រឡាច ល្ពៅ** | | | | | | | | | | | | | | | | | | |
| – ការរៀបចំដី (ប:៥0% –ស:៥0%) | | | | | | | | | | | | | | | | | | |
| – ការដាំ (ប:៣0% –ស:៧0%) | | | | | | | | | | | | | | | | | | |
| – ការថែទាំ (ប:៤0% –ស:៦0%) | | | | | | | | | | | | | | | | | | |
| –ប្រមូលផល (ប:៣0% –ស:៧0%) | | | | | | | | | | | | | | | | | | |
| **សណ្តែកទ្រើង** | | | | | | | | | | | | | | | | | | |
| – ការរៀបចំដី (ប:៥0% –ស:៥0%) | | | | | | | | | | | | | | | | | | |
| – ការដាំ (ប:៣0% –ស:៧0%) | | | | | | | | | | | | | | | | | | |
| – ការថែទាំ (ប:៤0% –ស:៦0%) | | | | | | | | | | | | | | | | | | |
| –ប្រមូលផល (ប:៣0% –s:៧0%) | | | | | | | | | | | | | | | | | | |
| **តំបន់ទំនាទាប** | | | | | | | | | | | | | | | | | | |
| – ការរៀបចំដី (ប:៧0% –ស:៣0%) | | | | | | | | | | | | | | | | | | |
| – ការដាំ (ប:៣0% –ស:៧0%) | | | | | | | | | | | | | | | | | | |
| – ការថែទាំ (ប:៣0% –ស:៧0%) | | | | | | | | | | | | | | | | | | |
| – ប្រមូលផល (ប:២0% –ស:៨0%) | | | | | | | | | | | | | | | | | | |

| បរិយាយ \ ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១0 | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ដំណាំរួមផ្សំ** | | | | | | | | | | | | | | | | | | |
| **តំបន់ទំនាបមធ្យម** | | | | | | | | | | | | | | | | | | |
| **ដំឡូងមី** | | | | | | | | | | | | | | | | | | |
| – ការរៀបចំដី (ប:៧0%–ស:៣0%) | | | | | | | | | | | | | | | | | | |
| – ការដាំ (ប:៥0%–ស:៥0%) | | | | | | | | | | | | | | | | | | |
| – ការថែទាំ (ប:៥0%–ស:៥0%) | | | | | | | | | | | | | | | | | | |
| – ប្រមូលផល (ប:៧0%–ស:៣0%) | | | | | | | | | | | | | | | | | | |
| – ការរៀបចំដី (ប:៧0%–ស:៣0%) | | | | | | | | | | | | | | | | | | |
| – ការដាំ (ប:៥0%–ស:៥0%) | | | | | | | | | | | | | | | | | | |
| – ការថែទាំ (ប:៥0%–ស:៥0%) | | | | | | | | | | | | | | | | | | |
| – ប្រមូលផល (ប:៧0%–ស:៣0%) | | | | | | | | | | | | | | | | | | |
| **ការចិញ្ចឹមសត្វ** | | | | | | | | | | | | | | | | | | |
| – គោ ក្របី (ប:៦0%–ស:៤0%) | | | | | | | | | | | | | | | | | | |
| – ជ្រូក (ប:៤0%–ស:៦0%) | | | | | | | | | | | | | | | | | | |
| – មាន់/ទា (ប:៥0%–ស:៥0%) | | | | | | | | | | | | | | | | | | |

| **បរិយាយ** ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ពលកម្មក្រៅភូមិ** | | | | | | | | | | | | | | | | | | |
| – កម្មករកាត់ដេរ,លក់សាំង ៣% (ប:១០%–ស:៩០%) | | | | | | | | | | | | | | | | | | |
| – ស៊ីឈ្នួលជាយដែនថៃ ៣% (ប:៩០%–ស:១០%) | | | | | | | | | | | | | | | | | | |
| **ការងារសង្គម** | | | | | | | | | | | | | | | | | | |
| – ចូលឆ្នាំខ្មែរ | | | | ☺ | | | | | | | | | | | | | | |
| – បុណ្យសុំទឹកភ្លៀង (ឡើងអ្នកតា) | | | | | ☺ | | | | | | | | | | | | | |
| – ភ្ជុំបិណ្ឌ | | | | | | | | | ☺ | | | | | | | | | |
| – បុណ្យពូនភ្នំស្រូវ | | ☺ | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| **តំរែកសិផល** | | | | | | | | | | | | | | | | | | |
| – ស្រូវ | | | | | | | | | | | | | | | | | | |
| – មាន់ | | | | | | | | | | | | | | | | | | |
| – ជ្រូក | | | | | | | | | | | | | | | | | | |
| – បន្លែ | | | | | | | | | | | | | | | | | | |

## ៣. ការវិភាគជីវភាពរស់នៅ

### ❖ ចំណាត់ថ្នាក់ធនធាន

កាលវិភាគចំណាត់ថ្នាក់ធនធានប្រើប្រាស់ដើម្បី យល់ដឹងអំពីសមភាព នឹងយល់ដឹងពីចរិកលក្ខណៈតម្រូវការ និងឱកាសសំរាប់ធនធាននីមួយៗ ជាពិសេសគ្រួសារក្រីក្រ ។

កាលវិភាគចំណាត់ថ្នាក់ធនធាននេះធ្វើឡើងនូវពេល ធ្វើការវាយតំលៃឆាប់រហ័សនៅជនបទ នៅពេលធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំដើម្បីសួរកសិករប៉ាន់ប្រមាណភាគរយ អ្នកក្រ អ្នកមធ្យម និងអ្នកគ្រាន់បើដែលរស់នៅក្នុងតំបន់ធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន។លើសពីតម្រូវការនេះទៀតប្រើប្រាស់ដើម្បីធ្វើការកំណត់ចរិកលក្ខណៈ អ្នកក្រ អ្នកមធ្យម និង អ្នកគ្រាន់បើ ។ ភាពខុសគ្នានៃចរិកលក្ខនៈទាំងនេះបង្ហាញនៅក្នុងតារាងខាងក្រោម ។

**បញ្ជីចំណាត់ថ្នាក់ធនធាននិមួយៗ**

គ្រួសារតាមថ្នាក់ធនធាននិមួយៗ មានកត្តាដូចខាងក្រោម :

- ទំហំកាន់កាប់ដី (ទំហំដី ប្រភេទដី ចំនួនក្បាលដី )
- ទំហំគ្រួសារ និងកំលាំងពលកម្ម
- ប្រភពប្រាក់ចំណូល
- ទំហំកាន់កាប់ដី ( ប្រភេទដី និង ទីតាំង )
- ទ្រព្យធនកសិដ្ឋាន ( ធារាសាស្ត្រ អណ្តូង ស្រះត្រី ។ល។)
- កំលាំងពលកម្ម ក្រៅពីកសិដ្ឋាន (ចំនួន និងប្រភេទ )
- ដំាដុះដំណាំ និងទីតាំង ដែលពាក់ព័ន្ធ
- ទិន្នផលដំណាំ និងការប្រើប្រាស់ទុន
- ចំនួនសត្វពាហនៈ និងការពាក់ព័ន្ធ
- សម្ភារៈកសិកម្ម ( ម្ចាស់ និងការប្រើប្រាស់ )
- ទីតាំងជលផល ឧបករណ៍នេសាទ និងសកម្មភាពការកែច្នៃជលផល
- ឧបករណ៍ជលផល ( ម្ចាស់ និងការប្រើប្រាស់ )
- ឥណទាន ( ការប្រើប្រាស់ និងប្រភពខ្ចី )

**ឧទាហរណ៍៖ ការកំណត់ប្រភេទកសិករអាស្រ័យធនធានតាមតំបន់**

✦ **តំបន់ទំនាបមធ្យម**

| **បង្គួរ (គ្រាន់បើ)** | **មធ្យម** | **ក្រ** |
|---|---|---|
| - ផ្ទះក្បឿងជញ្ជាំងក្តា<br>- ស្បៀងហូបគ្រប់គ្រាន់ និងសល់<br>- មានទូរទស្សន៍ ម៉ូតូ កង ស៊ីឌី<br>- សំភារៈប្រើប្រាស់គ្រប់គ្រាន់<br>- ម៉ាស៊ីនបោកស្រូវ<br>- ជួលកំលាំងពលកម្មធ្វើស្រែ | - ផ្ទះស័ង្កសី / ស្លឹក<br>- មានកង់<br>- មានទូរទស្សន៍ស ខ្មៅ<br>- មានរទេះ, រនាស់, នង្គ័ល<br>- ធ្វើស្រែដោយខ្លួនឯង និងប្រវ៉ាស់ដៃគ្នា<br>- ខ្វះស្បៀង១–២ខែ | - ផ្ទះខ្ទម / ស្លឹក<br>- គ្មានសំភារៈប្រើប្រាស់<br>- លក់កំលាំងពលកម្ម<br>- ជំពាក់បំណុលគេ<br>- ប្រវ៉ាស់សត្វគេចិញ្ចឹម |
| **ស្ថានភាពគ្រួសារគិតជាភាគរយៈនៅក្នុងឃុំ (តំបន់ទំនាបមធ្យម)** | | |
| **គ្រួសារបង្គួរ** | **គ្រួសារមធ្យម** | **គ្រួសារក្រីក្រ** |
| **11%** | **49%** | **40%** |

**ដ្យាក្រាម ៖ តាងភាគរយៈស្ថានភាពគ្រួសារនៅក្នុងឃុំ តំបន់ទំនាបមធ្យម**




**លំហូរការប្រើប្រាស់កំលាំងពលកម្មធៀប និង មុខរបរទៅតាមប្រភេទគ្រួសារក្នុង ១ ឆ្នាំ**

✦ **តំបន់ទំនាបមធ្យម**

- គ្រួសារបង្គួរ ៖ ធ្វើស្រែ**៥0%** បន្លែ**១0%** ចិញ្ចឹមសត្វ**២0%** ត្បាញកន្ទេល**៩%** លក់ដូរ**៥%** និងម៉ាស៊ីនបោកស្រូវ នឹងបញ្ចូលអាគុយ **៦%**
- គ្រួសារមធ្យម៖ ធ្វើស្រែ **៥0%** បន្លែ**១៥%** ចិញ្ចឹមសត្វ **២៥%** ត្បាញកន្ទេល **៦%** និងស៊ីឈ្នួល **៤%**
- គ្រួសារក្រីក្រ ៖ ធ្វើស្រែ **២0%** ដាំបន្លែ **២0%** ចិញ្ចឹមសត្វ**១0%**ស៊ីឈ្នួលគេ **៥0%**

**ដ្យាក្រាម : លំហូរការប្រើប្រាស់កំលាំងពលកម្មធៀប និងមុខរបរ តំបន់ទំនាបមធ្យម**




## តារាងធនធានសត្វពាហនៈក្នុងឃុំ តាមតំបន់

✧ **តំបន់ទំនាបមធ្យម**

| សត្វ | គ្រួសារបង្គួរ | គ្រួសារមធ្យម | គ្រួសារក្រ |
|---|---|---|---|
| គោ | **2.3** ក្បាល | **1** ក្បាល | **0.5** ក្បាល |
| ក្របី | **3** ក្បាល | **1** ក្បាល | **0** ក្បាល |
| ជ្រូក | **2** ក្បាល | **0.6** ក្បាល | **0.3** ក្បាល |
| មាន់ | **8** ក្បាល | **6** ក្បាល | **3** ក្បាល |

**ដ្យាក្រាម: តាងធនធានសត្វពាហនៈ តំបន់ទំនាបមធ្យម**




## បណ្ដាជំងឺលើសត្វចិញ្ចឹម

✦ **តំបន់ទំនាបមធ្យម**

### តារាង: ពេលវេលាសត្វឈឺ (គោ-ក្របី ជ្រូក និងមាន់)

| សត្វ | ធ្វើវ៉ាក់សាំង | ប្រភេទជំងឺ | ពេលវេលាឈឺ (ខែ) | ភាគរយកើតជំងឺ | ភាគរយស្លាប់ដោយជំងឺ | ភាគរយមិនស្លាប់ដោយជំងឺ |
|---|---|---|---|---|---|---|
| គោ-ក្របី | - បានធ្វើ | - សារទឹក | 4-5 | 20% | 2% | 18% |
| | - មិនបានធ្វើ | - អុតក្តាម | 4-5 | 15% | 0% | 15% |
| ជ្រូក | - មិនបានធ្វើ | - សារទឹក | 4-5 | 20% | 9% | 11% |
| | - មិនបានធ្វើ | - ប៉េស្ត | 4-5 | 20% | 20% | 0% |
| | - មិនបានធ្វើ | - កញ្ជ្រិល | 4-5 | 5% | 0% | 5% |
| មាន់ | - មិនបានធ្វើ | - អាសន្នរោគ | 3-6 | 80% | 80% | 0% |
| | - មិនបានធ្វើ | - ញូវកាស | 11-12 | 50% | 30% | 20% |
| | - មិនបានធ្វើ | - អ៊ុត | 11-12 | 50% | 15% | 35% |

### ដ្យាក្រាម : ដ្យាក្រាមភាគរយសត្វឈឺ តំបន់ទំនាបមធ្យម









## តារាងធនធានដីធ្លីក្នុងឃុំ

✧ **តំបន់ទំនាបមធ្យម**

| ប្រភេទដី | គ្រួសារបង្គួរ | គ្រួសារមធ្យម | គ្រួសារក្រ |
|---|---|---|---|
| ដីស្រែ | 4.5 ហិកតា | 1.6 ហិកតា | 0.5 ហិកតា |
| ដីចំការ | 0.25 ហិកតា | 0 ហិកតា | 0 ហិកតា |
| ដីលំនៅដ្ឋាន | 0.25 ហិកតា | 0.25 ហិកតា | 0.10 ហិកតា |




## តារាងប្រាក់ចំណូលជាមធ្យមតាមស្ថានភាពគ្រួសារ   តំបន់ទំនាបមធ្យម

**តំបន់ទំនាបមធ្យម**

| ផលិតផល | គ្រួសារបង្គួរ | គ្រួសារមធ្យម | គ្រួសារក្រ |
|---|---|---|---|
| ស្រូវ | 900.000 រៀល | 500.000 រៀល | 200.000 រៀល |
| បន្លែ | 300.000 រៀល | 300.000 រៀល | 100.000 រៀល |
| មាន់ | 400.000 រៀល | 400.000 រៀល | 150.000 រៀល |
| ជ្រូក | 1.000.000 រៀល | 500.000 រៀល | 200.000 រៀល |
| លក់ដូរ | 1.000.000 រៀល | 0 រៀល | 0 រៀល |
| ស៊ីឈ្នួល | 0 រៀល | 900.000 រៀល | 1.000.000 រៀល |
| ត្បាញកន្ទេល | 400.000 រៀល | 400.000 រៀល | 0 រៀល |
| ឈ្នួលម៉ាស៊ីនបោក | 2.500.000 រៀល | 0 រៀល | 0 រៀល |
| ឈ្នួលបញ្ចូលអាគុយ | 1.000.000 រៀល | 0 រៀល | 0 រៀល |
| **សរុប** | 7.500.000 រៀល | 3.000.000 រៀល | 1.450.000 រៀល |

**ផ្សាក្រាម: ប្រាក់ចំណូលជាមធ្យមតាមស្ថានភាពគ្រួសារ តំបន់ទំនាបមធ្យម**




**ប្រភពចំណូលសំខាន់ៗតាមស្ថានភាពគ្រួសារ**

| ប្រភេទចំណូល | គ្រួសារបង្គួរ | គ្រួសារមធ្យម | គ្រួសារក្រ |
|---|---|---|---|
| -ប្រភពចំណូលទី ១ | ស្រូវ | លក់កំលាំងពលកម្ម | ការងារក្រៅកសិកម្ម |
| -ប្រភពចំណូលទី ២ | ចិញ្ចឹមសត្វ | ចិញ្ចឹមសត្វ | រកធនធានធម្មជាតិ |
| -ប្រភពចំណូលទី ៣ | ដូង/ចិញ្ចឹមសត្វ | អំពៅ/ចិញ្ចឹមសត្វ | រកត្រី |

- **ការវិភាគយ៉េនឌ័រ**

ការអភិវឌ្ឍន៍កសិកម្មអាចជាផលប៉ះពាល់លើផ្នែកយ៉េនឌ័រទាំងវិជ្ជមាន និងអវិជ្ជមាន ដំណើរការទាំងនេះធ្វើឡើងនៅពេលធ្វើ ការវាយតំលៃជនបទឆាប់រហ័សដោយប្រើប្រាស់ឧបករណ៍វិភាគយ៉េនឌ័រ ។

**ជំហ៊ានសំខាន់ៗ :**

១. នៅពេលធ្វើការវាយតំលៃជនបទឆាប់រហ័ស និងការប្រើប្រាស់តារាងវិភាគយ៉េនឌ័រកំណត់ពីសកម្មភាពសំខាន់ៗនៃជីវភាពរស់នៅ

២. ព័ត៌មានទាំងនេះនឹងបង្ហាញក្នុងតារាងខាងក្រោម

៣. ព័ត៌មានពីតួនាទី រវាងបុរស និងស្ត្រី នៅក្នុងសកម្មភាពជីវភាពរស់នៅនឹងត្រូវបានកត់ត្រានៅក្នុងតារាងខាងក្រោម

៤. នៅក្នុងដំណាក់កាលការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ ប្រើប្រាស់នូវលទ្ធផលដែលបានពីការវិភាគយ៉េនឌ័រ ដើម្បីជួយក្នុងការកំណត់ពីភាពប៉ះពាល់នៃយ៉េនឌ័រ សំរាប់បង្កើតបទដ្ឋានអនុវត្តបច្ចេកវិជ្ជា នៅពេលធ្វើ ការកំណត់បច្ចេកវិជ្ជាថ្មី

**ការផ្ទៀងផ្ទាត់ការវិភាគយ៉េនឌ័រ**

ការផ្ទៀងផ្ទាត់ការវិភាគយ៉េនឌ័រត្រូវបានប្រើប្រាស់ដើម្បីកំណត់ពីសកម្មភាពសំខាន់ៗ នៃជីវភាពរស់នៅ ដោយប្រើប្រាស់ឧបករណ៍វិភាគយ៉េនឌ័រ ។

**ឧទាហរណ៍ : ការវិភាគយ៉េនឌ័រ**

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| **<u>សកម្មភាពស្រូវវស្សា</u>** | | | |
| – រៀបចំដីថ្នាលសំណាប | ✓✓ | | |
| – សាបគ្រាប់ពូជ | ✓ | ✓✓ | ស្ត្រីត្រាំពូជ បុរសចូលរួមសាប |
| – ដកសំណាប | ✓ | ✓✓ | ពេលខ្លះបុរសជួយស្ត្រីដែរ |
| – ដឹកជញ្ជូនសំណាប | ✓✓ | | |
| – រៀបចំដីស្រែសន្ទូង | ✓✓ | | |
| – ស្ទូង | ✓ | ✓✓ | |
| – បាចដី | ✓ | ✓ | ស្ត្រីអាចជួយជញ្ជូនដីយកទៅបាច់ដែរ |
| – ការគ្រប់គ្រងទឹក | ✓✓ | | |
| – សំអាតស្មៅ | ✓ | ✓ | |
| – ច្រូតកាត់ | ✓ | ✓✓ | |
| – ដឹកជញ្ជូនកណ្តាប់ស្រូវ | ✓✓ | ✓ | |
| – បោកបែន | ✓✓ | | |
| – រោយគ្រាប់ស្រូវ | | ✓✓ | បើរោយកង្ហារបក់បុរសជួយស្ត្រីដែរ |
| –ជញ្ជូនទុកដាក់ស្រូវ | ✓✓ | ✓ | |
| **<u>សកម្មភាពស្រូវប្រាំង</u>** | | | |
| – រៀបចំដី | ✓✓ | | |
| – ត្រាំគ្រាប់ពូជ | | ✓✓ | |
| – ព្រោះគ្រាប់ស្រូវ | ✓ | ✓ | |
| – បាចដី | ✓ | ✓ | ស្ត្រីជួយជញ្ជូនដីទៅស្រែដែរ |
| – ការគ្រប់គ្រងទឹក | ✓✓ | | |
| – សំអាតស្មៅ | ✓ | ✓ | |
| – កំចាត់សត្វល្អិត និងបាញ់ថ្នាំ | ✓✓ | | |

| | | | |
|---|---|---|---|
| - លើកភ្លឺស្រែ | ✓✓ | | |
| - ច្រូតកាត់ | ✓ | ✓✓ | |
| - ដឹកជញ្ជូនកណ្តាប់ស្រូវ | ✓✓ | ✓ | |
| - បោកបែន | ✓✓ | ✓ | |
| - រោយគ្រាប់ស្រូវ | | ✓✓ | |
| - ដឹកជញ្ជូនគ្រាប់ស្រូវ | ✓✓ | | |
| - រៀបចំទុកដាក់គ្រាប់ស្រូវ | ✓✓ | | |
| **<u>សកម្មភាពចិញ្ចឹមសត្វនិងប្រកបរបរផ្សេងទៀត</u>** | | | |
| - ស្ទូនដំណាំគ្រួសារ | ✓ | ✓ | |
| - ការចិញ្ចឹមគោ | ✓✓ | ✓ | |
| - ការចិញ្ចឹមជ្រូក | ✓ | ✓✓ | |
| - ប្រមូលអនុផលធនធានធម្មជាតិ | ✓✓ | ✓ | |
| - រកអុសដុត | ✓✓ | | |
| - សិប្បកម្មតម្បាញ | ✓ | ✓✓ | |
| - រកត្រី | ✓✓ | | |
| - លក់ដូរ | | ✓✓ | |
| - ជួសជុលប្រព័ន្ធស្រោចស្រព | ✓✓ | | |
| - ដងទឹក | ✓ | ✓ | |
| - កម្មកររោងចក្រ | | ✓✓ | |
| - កម្មករសំណង់/ស៊ីឈ្នួលគេ | ✓✓ | | |
| **សកម្មភាពជលផល** | | | |
| - រកត្រី (ក្នុងស្រែ ស្រះ បឹង ទន្លេ ...) | ✓✓ | | |
| - លក់ត្រី (ក្តាម ខ្យង កំពឹស កង្កែប អណ្តើក...) | ✓ | ✓ | |
| - ការច្នៃផលិតផល (ត្រីងៀត ត្រីឆ្អើរ ផ្អក មាំ ប្រហុក..) | | ✓✓ | |
| - ការប្រមូលទុកដាក់ផលិតផលកែច្នៃរួច | ✓ | ✓ | |
| - ការធ្វើឧបករណ៍នេសាទ (ទ្រូ លប អួន សន្ទូចរនង...) | ✓✓ | | |
| - រកត្រី និងវារីជាតិ សំរាប់ហូបជាលក្ខណៈគ្រួសារ | ✓✓ | | |
| - ចូលរួមក្នុងការងារសហគមន៍នេសាទ | ✓ | ✓ | |

| | | | |
|---|---|---|---|
| **សកម្មភាពចិញ្ចឹមត្រី** | | | |
| – ទីផ្សារ | | | |
| – ការកែច្នៃ | | | |
| – ការប្រើប្រាស់ជាលក្ខណៈគ្រួសារ | | | |
| – ការធ្វើឧបករណ៍ចិញ្ចឹមត្រី | | | |
| **សកម្មភាពសេដ្ឋកិច្ច** | | | |
| – លក់ផលិតផលកសិកម្ម | | | |
| – ទទួលប្រាក់កំចី | | | |
| – ការជួញដូរ | | | |
| – ការចំណាយ | | | |

❖ **ការវិភាគពីទ្រព្យធន ជីវភាពរស់នៅ**

ឧបករណ៍នេះប្រើប្រាស់ដើម្បីស្វែងយល់ការវិភាគប្រព័ន្ធជីវភាពដើម្បីឱ្យយល់ពីរបៀបការរស់នៅការផលិតទៅតាមតំរូវការចាំបាច់របស់គ្រួសារ។ ការវិភាគតំរូវការចាំបាច់មានៈ អាហារ ជំរក ថាមពល សុខភាព ឬថ្នាំសង្កូវ ថវិកា និងការសន្សំ ។

**ជំហ៊ានសំខាន់ៗ** :

១. ប្រព័ន្ធការវិភាគជីវភាព គឺជាប្រធានបទដើម្បីវិភាគធនធាននៅ ពេលធ្វើការវាយតំលៃឆាប់រហ័សនៅជនបទ ។

២. តារាងឧទាហរណ៍នឹងបង្ហាញនូវទំព័របន្ទាប់ តារាងខាងឆ្វេងបង្ហាញពីតំរូវការចាំបាច់ និង ចំណាត់ថ្នាក់ ទ្រព្យធននៅក្នុងតារាងទី ២

៣. ដំណើរការនៃការវិភាគធ្វើទៅតាមគោលបំណងរបស់កសិករ ប្រព័ន្ធក្នុងការផលិត ហើយនឹងបញ្ហាទៅតាមតំរូវការអ្នកធូរធារ អ្នកមធ្យម និងអ្នកក្រ និងដាក់បញ្ចូលនៅក្នុងតារាង

៤. នៅក្នុងដំណាក់កាលការវិភាគប្រព័ន្ធក្សេត្រ–បរិស្ថានថ្នាក់ឃុំ ប្រើប្រាស់នូវលទ្ធផលដែលបាន ពីការវិភាគទ្រព្យធនជីវភាពរស់នៅ ដើម្បីអោយប្រាកដនូវអ្វីដែលជា តំរូវការចាំបាច់សំរាប់ជីវភាពរស់នៅដែលជាមូលដ្ឋានគ្រឹះរបស់អ្នកក្រីក្រ សំរាប់កំណត់អាទិភាពនៅពេលបង្កើតបទដ្ឋានអនុវត្តបច្ចេកវិជ្ជា ។

**ឧទាហរណ៍ : ការវិភាគពីទ្រព្យធន ជីវភាពរស់នៅ**

| តំរូវការជាចាំបាច់ | ចំណាត់ធនធាន | គោលបំណង | ប្រព័ន្ធផលិត | បញ្ហា |
|---|---|---|---|---|
| ស្បៀង | អ្នកធូរធារ | អាហារមានគុណភាព | ទិញ | តម្លៃ |
| | អ្នកមធ្យម | អាហារមានជីវជាតិ | ផលិត និងទិញ | ទិន្នផល និង ប្រាក់ចំណូលគ្រប់គ្រាន់ |
| | អ្នកក្រ | ខ្វះលទ្ធភាពក្នុងការរកស្បៀង | ផលិត និងប្រមូលផល | ទិន្នផល វារីជាតិ និង អនុផលព្រៃឈើ ខ្វះដីស្រែចំការ |
| ថាមពល | អ្នកធូរធារ | សន្សំពេលវេលា | ទិញប្រេង ឬហ្គាស | មានលក់ក្នុងភូមិ |
| | អ្នកមធ្យម | ងាយស្រួលប្រើ | ធ្យូង | មានស្រាប់ និងទិញ |
| | អ្នកក្រ | ធនធានអាចរកបាន | អុស | មានស្រាប់ |
| ផ្ទះសំបែង | អ្នកធូរធារ | ស្រួលរស់នៅ | កេរ្តមរតក | គ្មានភ្លើងប្រើប្រាស់ |
| | អ្នកមធ្យម | មានសុវត្ថិភាព | ទិញសំភារៈសាងសង់ | ចំណាយថវិកា |
| | អ្នកក្រ | ផ្ទះខ្ទម | សំភារៈសាងសង់មានស្រាប់ក្នុងភូមិ | ឧបករណ៍មានស្រាប់ |
| សុខភាព និង ថ្នាំសង្កូវ | អ្នកធូរធារ | សុខភាពល្អ | មណ្ឌលសុខភាព | ពេលវេលាធ្វើដំណើរ |
| | អ្នកមធ្យម | អាចធ្វើការបាន | មណ្ឌលសុខភាពថ្នាក់ឃុំ | ចំណាយថវិកា |
| | អ្នកក្រ | សុខភាពទន់ខ្សោយ | ឱសថបុរាណអាចទទួលសេវាសុខភាពពីភ្នាក់ងារសុខភាព | ព្យាបាលខ្លួនឯង និង មានឱសថបុរាណក្នុងភូមិ |
| ថវិកា | អ្នកធូរធារ | លំហែកាយ | រកស៊ីតូចតាច រាជការ | បញ្ហាមុខរបររកស៊ី |
| | អ្នកមធ្យម | បញ្ជូនកូនទៅរៀន | ប្រព័ន្ធកសិកម្ម | តំលៃទីផ្សារទាប |
| | អ្នកក្រ | ទិញស្រូវ | លក់កំលាំងពលកម្ម | ស្រូវថ្លៃ |
| ប្រាក់សន្សំ | អ្នកធូរធារ | ចូលនិវត្តន៍ (វ័យចាស់) | មានលុយចងការ មានចំការ | សេដ្ឋកិច្ចប្រែប្រួល |
| | អ្នកមធ្យម | រៀបការ ការកូន បុណ្យទាន | គោ ក្របី | គោ ក្របីមានជំងឺ |
| | អ្នកក្រ | បុលគេបើមានការចាំបាច់ | ជួយឧបត្ថម្ភពីសាច់ញាតិ | គ្មានលទ្ធភាពរកប្រាក់សន្សំ |

## ៤. ការវិភាគលំហូរ

### ❖ ដ្យាក្រាមលំហូរ

ដ្យាក្រាមលំហូរត្រូវបានប្រើប្រាស់ដើម្បីធ្វើការវិភាគពីទុន ថវិកា ព័ត៌មាន កំលាំងពលកម្ម ។ល។ លំហូរនេះអាចហូរចេញ និងហូរចូលទៅតាមឋានានុក្រម ។ ឧទាហរណ៍ : ពីភូមិទៅស្រុក ឬខេត្ត និងពី តំបន់ប្រព័ន្ធកេ្សត្រ-បរិស្ថានមួយទៅតំបន់ដ៏ទៃទៀត ។ ឧទាហរណ៍ : ការរកស្មៅរបស់សត្វពាន:ពីតំបន់មួយទៅតំបន់មួយទៅតាមរដូវកាល (ដូចមាននៅក្នុងឧទាហរណ៍ )។

**ជំហ៊ានសំខាន់ៗ :**

១. គូសរង្វង់មូល ឬដ្យាក្រាមមូលបង្ហាញអំពីប្រព័ន្ធនៃឋានានុក្រម និងតំបន់កេ្សត្រ-បរិស្ថានដែលមាននៅក្នុងឃុំ ដូចមានបង្ហាញនៅក្នុងឧទាហរណ៍

២. អ្នកភូមិ ធ្វើការកត់ត្រាលំហូរចេញ និងលំហូរ និងពីតំបន់មួយទៅតំបន់មួយ

៣. ឆ្លងតាមការពិភាក្សាជាមួយអ្នកភូមិ ធ្វើការកំណត់ពីឧបសគ្គ បញ្ហា និងឱកាសដែលបាត់បង់ដែលទាក់ទងទៅនឹងលំហូរ

៤. ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ដ្យាក្រាមលំហូរ ដើម្បីអោយប្រាកដថា ផ្នែកសំខាន់ៗទាំងអស់ ត្រូវបានរាប់បញ្ចូល

**បញ្ជីផ្ទៀងផ្ទាត់ដ្យាក្រាមលំហូរ**

បញ្ជីផ្ទៀងផ្ទាត់នេះនឹងត្រូវបានប្រើប្រាស់ដើម្បីកំណត់ពីសារៈសំខាន់នៃលំហូរដែលធ្វើការវិភាគជាមួយអ្នកភូមិនៅពេលធ្វើការវាយតំលៃជនបទឆាប់រហ័ស

- ❖ លំហូរដើមទុនកសិកម្ម (ជី ថ្នាំកសិកម្ម ចំណី កូនត្រី ...។ល។)
- ❖ ផលិតផលកសិដ្ឋាន (ដំណាំ បសុពេទ្យ ជលផល អនុផលព្រៃឈើ )
- ❖ ឧបករណ៍កសិកម្ម (ត្រាក់ទ័រ ម៉ាស៊ីនច្រូត ឧបករណ៍នេសាទ)
- ❖ ព័ត៌មានកសិកម្ម (បច្ចេកទេស ព័ត៌មានទីផ្សារ ទុន...។ល។)
- ❖ រដូវការចំណាកស្រុក (ស្ត្រី និងបុរស)
- ❖ លំហូរកំលាំងពលកម្ម (ក្នុងកសិដ្ឋាន និងក្រៅកសិដ្ឋាន)
- ❖ ឥណទាន (ផ្លូវការ ក្រៅផ្លូវការ)
- ❖ អនុផលព្រៃឈើ (ប្រើប្រាស់ និងលក់)
- ❖ សកម្មភាពបសុសត្វ (វាលស្មៅ លក់ )
- ❖ បំលាស់ទីរបស់ត្រី
- ❖ សំភារៈសំរាប់កែច្នៃ (ផលិតផលកសិកម្ម ជលផល អនុផលព្រៃឈើ ស្ករត្នោត ។ល។ )
- ❖ ផ្សេងៗ ដូចជា ( ភាពសំខាន់ៗនៅក្នុងតំបន់)

❖ **ឧទាហរណ៍ : ដ្យាក្រាមលំហូរព័ត៌មានសេដ្ឋកិច្ច និងទំនាក់ទំនងរវាងតំបន់កេ្សត្រ-បរិស្ថាន**



❖ **ការប្រើប្រាស់អនុផលព្រៃឈើ របស់ឃុំ**

**តារាងការប្រើប្រាស់អនុផលព្រៃឈើ និងអនុផលធនធានធម្មជាតិ**

| ល.រ | ប្រភេទអនុផល | ប្រភព | ការប្រើប្រាស់ | ស្ថានភាពធនធាន (សម្បូរ ឬថយចុះ) | ពេលវេលារកអនុផល (ខែ ឬ រដូវកាល) | អ្នករក ស្ត្រី ឬបុរស |
|---|---|---|---|---|---|---|
| ១ | រកអុសដុត | | | | | |
| ២ | រកជ័រចុង | | | | | |
| ៣ | រកទំពាំងព្រៃ | | | | | |
| ៤ | រកវល្លិ | | | | | |
| ៥ | រកបន្លែព្រៃ (ស្លឹកប្រិច,រងៀង) | | | | | |
| ៦ | រកផ្សិតព្រៃ | | | | | |
| ៧ | រកផ្លែឈើព្រៃ (គុយ, ភ្លៀវ,....) | | | | | |

## ៥. ការវិភាគសេដ្ឋកិច្ច និងការសំរេចចិត្ត

❖ **ការវិភាគបុព្វហេតុ និងផលប៉ះពាល់**

**ខ្វះពូជស្រូវថ្មីផ្តល់ទិន្នផលខ្ពស់**



**ដីខ្សោះជីជាតិ ៖**


ខ្វះកំលាំងអូសទាញ
សត្វឈើ
ខ្វះស្បៀង
ចំណូលតិច ឬ ខាត
ខ្វះចំណីសត្វ
ទិន្នផលស្រូវទាប
ចំណាយច្រើន
ដីខ្សោះជីជាតិ
ការហូរច្រោះ
ការប្រើជីធម្មជាតិនូវមានកំរិត
ដំណាំតែមួយមុខ
ប្រើតែជីគីមី
បាត់បង់ព្រៃធម្មជាតិ
ខ្វះការយល់ដឹង
ខ្វះការសន្សំជី
មិនបានដាំជីស្រស
ចិញ្ចឹមសត្វលែង
ខ្វះការយល់
ខ្វះប្រភពទឹក
ដីមិនអំណោយផល
ខ្វះការយល់ដឹង
មិនទំលាប់

## ខ្វះបច្ចេកទេសដាំដុះស្រូវ



❖ **ដ្យាក្រាមវ៉ែន**

ដ្យាក្រាមវ៉ែនប្រើសំរាប់វិភាគអំពីទំនាក់ទំនងរវាងប្រព័ន្ធកៀ្សត្រ–បរិស្ថានឃុំ និងគំរោង ឬទីភ្នាក់ងារដែលជួយគាំទ្រដល់ពួកគាត់ ។ ដ្យាក្រាមវ៉ែននេះមានសារៈសំខាន់ក្នុងការ កំណត់នូវសក្តានុពលដែគួរអភិវឌ្ឍ ឬរកឃើញនូវការសហការរវាងស្ថាប័នមួយទៅស្ថាប័នមួយទៀត ។ នៅក្នុងវ៉ែនដ្យាក្រាមរង្វង់ដែលត្រួតស៊ីគ្នាគឺបង្ហាញអំពីការសហការល្អ និងរង្វង់ដែលប៉ះគ្នា ឬមិនមានការប៉ះគ្នា គឺបង្ហាញពីការសហការគ្នាខ្លះ ឬក៏គ្មានការសហការ ។

**ឧទាហរណ៍ : ដ្យាក្រាមបង្ហាញពីជំនួយឧបត្ថម្ភការងារអភិវឌ្ឍន៍**




**សញ្ញាសំគាល់**

 គ្មានទំនាក់ទំនង

 មានការទំនាក់ទំនងក្នុងការផ្លាស់ប្តូរព័ត៌មាន

 មានការសហការក្នុងការសំរេចចិត្ត

 មានការសហការល្អក្នុងការសំរេចចិត្ត

❖ **ការវិភាគសេដ្ឋកិច្ច**

ការវិភាគសេដ្ឋកិច្ចដើម្បីបង្ហាញអោយកាន់តែយល់ច្បាស់នូវប្រព័ន្ធផលិតកម្មក្នុងតំបន់ និងដើម្បីជួយទិន្នផលកើនហើយនិងប្រាក់ចំណេញ ។ ការវិភាគសេដ្ឋកិច្ចតាមបែបបុរាណក៏អាចប្រើដើម្បីប្រៀបធៀប និងសំរាប់កែលំអនូវការអនុវត្តន៍(ការវិភាគសេដ្ឋកិច្ច បទដ្ឋានអនុវត្តបច្ចេកវិជ្ជា) ដើម្បីជួយកសិករក្នុងការកំណត់នូវឱកាសសំរាប់កែលំអប្រព័ន្ធកសិកម្មរបស់ពួកគាត់ ។

**ជំហានសំខាន់ៗ** :

១. ការវិភាគសេដ្ឋកិច្ចនឹងផ្តោតលើ ៣ផ្នែកសំខាន់ៗជាពិសេសប្រាក់ចំណូលរួមបញ្ចូលរួមមានដំណាំ បសុសត្វ និងសេវាជលផល

២. ចំពោះត្រី និង អនុផលព្រៃឈើ ការវិភាគសេដ្ឋកិច្ចវិភាគតែលើវារីជាតិ ឬ អនុផលព្រៃឈើដែលបានប្រើប្រាស់ដោយមិនរាប់បញ្ចូលប្រព័ន្ធពីធម្មជាតិ

៣. ការវិភាគសេដ្ឋកិច=គឺជាគន្លឹះដើម្បីធ្វើការអភិវឌ្ឍន៍ជាមួយកសិករ ដោយប្រើប្រាស់ព័ត៌មានដែលបានពីការធ្វើវាយតំលៃជនបទឆាប់រហ័ស។

**បញ្ជីវិភាគសេដ្ឋកិច្ច**

បញ្ជីវិភាគសេដ្ឋកិច្ចនឹងត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីតំលៃចំណាយចំណូលទាំងអស់

| ទុន | ប្រាក់ចំណូល |
|---|---|
| **បសុសត្វ :**<br>- ទិញ/ចំណាយលើការបង្កាត់<br>- ចំណី<br>- វ៉ាក់សាំង/ថ្នាំ<br>- កំលាំងពលកម្ម (កំលាំងខ្លួនឯង និងជួលគេ)<br>- ការដឹកជញ្ជូន<br>- តំលៃចំណាយផ្សេងៗ (ជាក់លាក់) | - តំលៃដែលទទួលបាន<br>- ដោយលក់ (ស៊ុត ទឹកដោះ ...។ល។)<br>- ប្រាក់ចំណូលផ្សេងៗ (ជាក់លាក់) |

| | |
|---|---|
| **ត្រី**<br>– តំលៃកូនត្រី<br>– ចំណីត្រី<br>– តំលៃកំលាំងពលកម្ម<br>– តំលៃដឹកជញ្ជូន<br>– តំលៃសំភារៈ (ម៉ាស៊ីនបូមទឹក ប៉ែរ ។ល។)<br>– តំលៃបូមទឹក<br>– តំលៃកែច្នៃ<br>– តំលៃទីផ្សារ<br>– កំលាំងពលកម្ម (កំលាំងខ្លួនឯង និងជួលគេ)<br>– តំលៃចំណាយផ្សេងៗ (ដាក់លាក់) | – ទិន្នផល<br>– ការបាត់បង់ក្រោយប្រមូលផល<br>– តំលៃដែលទទួលបាន<br>– តំលៃលក់ផលិតផល<br>– តំលៃអតិថិជនប្រើប្រាស់<br>– ប្រាក់ចំណូលផ្សេងៗ (ដាក់លាក់) |

**ឧទាហរណ៍ : ការវិភាគសេដ្ឋកិច្ចដំណាំស្រូវពង្រួសឡើងទឹក តំបន់ទំនាបទាប**

ចំណាយលើការដាំដុះស្រូវលើផ្ទៃដី ១ ហិចតា

- គ្រាប់ពូជ........................... ១០០ គក្រ x ៦០០ រៀល = ៦០ ០០០ រៀល
- ការរៀបចំដី .................... ១ហិចតា x ៧០ ០០០រៀល = ៧០ ០០០ រៀល
- ព្រួស...............................២នាក់ x ១ថ្ងៃ x ៥ ០០០រៀល = ១០ ០០០ រៀល
- ការថែទាំ .......................... ១៥ ថ្ងៃ x ៣ ៥០០រៀល = ៥២ ៥០០ រៀល
- ប្រមូលផល...........................១ហិចតា x ៦០ ០០០រៀល = ៦០ ០០០ រៀល
- ឈ្នួលបោក........................ ១ហិចតា x ២៤ ០០០ រៀល = ២៤ ០០០ រៀល
- ហាលសំងួត................២នាក់ x ២ថ្ងៃ x ៣០០០ រៀល = ១២០ ០០០ រៀល
- ការដឹកជញ្ជូន......................១៥ ដឹក x ៥០០០រៀល = ៧៥ ០០០ រៀល
- សរុបចំណាយ.......................................................... = ៤៧១ ៥០០ រៀល
- ទិន្នផល ១ ០០០ គក្រ ក្នុង ១ហិកតា
- តំលៃក្នុង 1 គ.ក្រ .................................. ៤៧១ ៥០០ រៀល = ៤៧៥,៥ រៀល
- ថ្លៃលក់ស្រូវក្នុងមួយគ.ក្រ : .................................................. = ៤៥០ រៀល/គក្រ
- ប្រាក់ចំណេញសុទ្ធក្នុង 1 គីឡូក្រាម : ៤៥០ រៀល – ៤៧៥,៥ រៀល = ២១,៥ រៀល/គក្រ

❖ **ការវិភាគចង្វាក់ផលិតកម្ម**

ផែនទី ការវិភាគចង្វាក់ផលិតកម្មបង្ហាញយើងឱ្យយល់ពីទំនាក់ទំនងទីផ្សារ បញ្ហា ឱកាស ដែលមានសារៈសំខាន់សំរាប់ជីវភាពរស់នៅ (ដំណាំ ចិញ្ចឹមសត្វ ត្រី អនុផលព្រៃឈើ ។ល។) ។ ផែនទីចង្វាក់ផលិតកម្មបង្ហាញអំពីលំហូរផលិតផលតាមរយៈចង្វាក់ទីផ្សារ និងជួយកំណត់ទីកន្លែង និងការដាក់បន្ថែមនូវតំលៃផលិតផល ដោយមានសកម្មភាពខុសៗគ្នានៅក្នុងចង្វាក់ផលិតកម្ម ។ ការវិភាគពេលលេញនៅក្នុងផែនទីចង្វាក់ផលិតកម្មអាចឱ្យយើងដឹងតំលៃទីផ្សារ ឧបសគ្គ ដើម្បីកំណត់ជំរើស ដ៏ទៃទៀតសំរាប់ធ្វើអោយប្រសើរឡើងនូវតំលៃបន្ថែមដោយខ្សែចង្វាក់ផលិតកម្ម។លទ្ធផលផែនទីនៃចង្វាក់ខ្សែផលិតកម្មប្រើប្រាស់ដើម្បីរៀបចំផែនការទីផ្សារឬបទអន្តរាគមន៍នានាៗដែលមានទំនាក់ទំនងជាមួយបទដ្ឋានអនុវត្តបច្ចេកវិជ្ជា ។ ចង្វាក់ផលិតកម្មនីមួយៗខុសគ្នាទៅតាមផលិតផលរបស់វា។ ឧទាហរណ៍ផលិតកម្មដំណាំស្រូវ ត្រី ឬការកែច្នៃប្រហុកជាលក្ខណៈគ្រួសារ ដែលមានលក្ខណៈសាមញ្ញ និងប្រើប្រាស់រយៈពេលខ្លី នេះគឺជាប្រភេទនៃផ្នែកមួយប៉ុណ្ណោះ ។ទោះជាយ៉ាងណាក៏ដោយចង្វាក់ផលិតកម្ម ត្រីនៅទន្លេសាបមានតំលៃខ្ពស់ទៅបានដោយសារ ការកែច្នៃ ដូចជា ត្រីងៀត ការវេចខ្ចប់ ធ្វើអោយមានគុណភាព ការអនុវត្តន៍បែបនេះមានភាពស្មុគស្មាញ និងចំណាយពេលវេលាយូរ ដោយមានអ្នកចូលរួមជាច្រើនផ្នែក (អ្នកនេសាទត្រី អ្នកផលិត ឈ្មួញកណ្តាល អ្នកបោះដុំ អ្នកនាំចេញ ។ល។ )

**ជំហ៊ានសំខាន់ៗ :**

១. នៅពេលធ្វើអង្កេតទិន្នន័យលើកដំបូង នៃការធ្វើការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ ផ្តោតទៅលើ ៣ចំនុចសំខាន់ៗ មុខរបរនៅក្នុងឃុំ ជាពិសេសប្រាក់ចំណូលដែលបានមកពី ការប្រើប្រាស់ផែនទីចង្វាក់ផលិតកម្ម (ប្រើមុខរបរដូចនៅក្នុងការវិភាគសេដ្ឋកិច្ច)

